សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights





# ការតស៊ូដើម្បីសេរីភាព

## ការរំលោភបំពានអ្នកការពារសិទ្ធិមនុស្ស ២០១៨ - ២០២០

របាយការណ៍សង្ខេប

ចេញផ្សាយ ខែធ្នូ ឆ្នាំ២០២០

# ការតស៊ូដើម្បីសេរីភាព

## ការរំលោភបំពានអ្នកការពារសិទ្ធិមនុស្ស ២០១៨ - ២០២០

របាយការណ៍សង្ខេបចេញផ្សាយ ខែធ្នូ ឆ្នាំ២០២០


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះ ពី ការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា




ការធ្វើទុក្ខបុកម្នេញទៅលើអ្នកការពារសិទ្ធិមនុស្ស ទំព័រ១

ការដាក់កំហុសលើការជួបជុំគ្នា ទំព័រ៣

ការចេញតវ៉ាតាមដងផ្លូវ ទំព័រ៧

សេរីភាពក្នុងការបញ្ចេញមតិ ទំព័រ១២

ការបង្កើនចំនួនច្បាប់ដែលមានលក្ខណៈរឹតត្បិត ទំព័រ១៦

ការដើរឆ្ពោះទៅមុខ ទំព័រ១៨

អនុសាសន៍ ទំព័រ១៩

ឧបសម្ព័ន្ធ៖ ការរំលោភបំពានទៅលើអ្នក
ការពារសិទ្ធិមនុស្សថ្មីៗនេះ ទំព័រ២០




អ្នកគាំទ្រប្រធានសហជីព លោក រ៉ុង ឈុន ដែលត្រូវជាប់ឃុំ ប្រមូលផ្តុំគ្នាអំពាវនាវឱ្យដោះលែង
អ្នកការពារសិទ្ធិមនុស្សដែលត្រូវបានចាប់ខ្លួនក្នុង ឆ្នាំ២០២០

# ការធ្វើទុក្ខបុកម្នេញទៅលើអ្នកការពារសិទ្ធិមនុស្ស

ទោះបីជាគណបក្សកាន់អំណាចទទួលបានអាសនៈទាំងអស់ក្នុងរដ្ឋសភា និងគ្រប់គ្រងរដ្ឋាភិបាល ក៏ប្រជាពលរដ្ឋកម្ពុជាជាច្រើននៅទូទាំងប្រទេសបន្តក្រោកឈរឡើង ដើម្បីទាមទារសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន ។ សហគមន៍កសិករនៅតាមតំបន់ជនបទ បានជួបជុំគ្នាដង្ហែក្បួនដោយអហិង្សានៅក្នុងរាជធានីភ្នំពេញ ដើម្បីស្វែងរកដំណោះស្រាយលើការរឹបអូសយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ ដែលធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារបាត់បង់ដីធ្លី និងជីវភាពរស់នៅ ។ សកម្មជនបរិស្ថាន ដើរល្បាតព្រៃឈើតាមតំបន់ដាច់ស្រយាល និងជ្រលងភ្នំ ដើម្បីអភិរក្សកេរ្តិ៍ដំណែលដែលបន្សល់ទុកជាយូរមកហើយ ពីក្រុមហ៊ុនសហគ្រាសឯកជន និងឧកញ៉ាដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកមានអំណាច ដែលធ្វើជំនួញគិតពីប្រាក់ចំណេញច្រើនហួសហេតុ ។

កម្មករ-កម្មការិនី សិស្ស-និស្សិត និងព្រះសង្ឃ ជំនាន់ក្រោយនៅតែចេញ តវ៉ានៅតាមដងផ្លូវ ដើម្បីអំពាវនាវឱ្យមានការគោរពសិទ្ធិរបស់អ្នកទាំងនោះ/ព្រះអង្គ ។ ហើយទោះបីជាប្រឈមនឹងហានិភ័យនៃការជាប់ពន្ធនាគារ ឬស្ថានភាពធ្ងន់ធ្ងរជាងនេះទៀត អ្នកសារព័ត៌មានជាច្រើន នៅតែបន្តរាយការណ៍អំពីការទាមទារតស៊ូប្រចាំថ្ងៃរបស់សហគមន៍ក្រីក្រ និងសហគមន៍ដែលគេមិនអើពើដែលប្រឈមនឹងវិសមភាពជាច្រើន ។

ក្នុងអំឡុងពេល ៣ឆ្នាំចាប់តាំងពី សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានចេញផ្សាយរបាយការណ៍ចុងក្រោយ ស្តីពីការធ្វើទុក្ខបុកម្នេញទៅលើអ្នកការពារសិទ្ធិមនុស្ស ពីសំណាក់អាជ្ញាធររដ្ឋ តុលាការបានរំលាយគណបក្សជំទាស់ធំជាងគេគឺ គណបក្សសង្គ្រោះជាតិ (CNRP) ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានបក្សតែមួយ និងធ្វើឱ្យសកម្មជនដែលមិនមែនជាអ្នកនយោបាយ ងាយរងគ្រោះកាន់តែខ្លាំងជាមុនទៅទៀត ពីការកើនឡើង នៃការត្រួតពិនិត្យចាប់ពិរុទ្ធ របស់រាជរដ្ឋាភិបាល ។ បច្ចុប្បន្ននេះ អាសនៈទាំង ១២៥ នៅរដ្ឋសភា គ្រប់គ្រងដោយគណបក្សកាន់អំណាច ។ មន្ត្រីឃុំ-សង្កាត់ជាង ៥០០០នាក់ ដែលប្រជាពលរដ្ឋបានជ្រើសរើស ឱ្យក្លាយជាអ្នកតំណាងរបស់ខ្លួននៅក្នុងការ បោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់កាលពីឆ្នាំ២០១៧ ត្រូវបានជំនួសដោយសមាជិកគណបក្សកាន់អំណាចទៅវិញ ។ បណ្តាញសារព័ត៌មានជាច្រើន ដែលសាធារណជនយល់ថា ឯករាជ្យ ឬមិនស្ថិតក្រោមឥទ្ធិពល របស់

គណបក្សកាន់អំណាចត្រូវបានបិទ ឬទិញដោយបុគ្គល ដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល ។ ច្បាប់ដែលមានលក្ខណៈរឹតត្បិតត្រូវបានអនុម័តជាស្វ័យប្រវត្តិដោយស្ថាប័ននីតិប្បញ្ញត្តិ ដែលគ្រប់គ្រងដោយគណបក្សកាន់អំណាច និងអនុវត្តដោយតុលាការដែលសាធារណជនយល់ថាខ្វះឯករាជ្យភាព ដើម្បីធ្វើយ៉ាងណារឹតត្បិតឱ្យកាន់តែតូចនៃលំហការងាររបស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើប្រតិបត្តិការ និងតស៊ូមតិសម្រាប់សាធារណជន ។

របាយការណ៍នេះមិនមានបំណង បង្ហាញពីតួលេខទាំងមូលនៃការធ្វើទុក្ខបុកម្នេញទៅលើអ្នកការពារសិទ្ធិមនុស្ស ចាប់តាំងពីដើម ឆ្នាំ ២០១៨ នោះទេ ។ ប៉ុន្តែរបាយការណ៍នេះ ចង់បង្ហាញពីតួលេខនៃករណីមួយចំនួន ដែលប្រជាពលរដ្ឋចាប់អារម្មណ៍ច្រើនដោយអ្នកការពារសិទ្ធិមនុស្ស ត្រូវទទួលរងការបំភិតបំភ័យ ការចាប់ខ្លួន ឬការឃុំខ្លួនក្នុងពន្ធនាគារ ដោយសារអ្នកទាំងនោះព្យាយាមប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការជួបជុំ ប្រមូលផ្តុំ និងបញ្ចេញមតិដោយអហិង្សា ដែលធានា ដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ។ ឧបសម្ព័ន្ធនៃរបាយការណ៍នេះ ដែលបរិយាយករណីច្រើនគិតពីដើមឆ្នាំ ២០១៨ រហូតដល់ខែដែលចេញរបាយការណ៍នេះ គឺប្រមូលបានពីការងាររបស់គម្រោងឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការ លីកាដូ ដើម្បីបង្ហាញលម្អិតកាន់តែទូលំទូលាយ នូវលំនាំនៃការធ្វើទុក្ខបុកម្នេញមួយចំនួនទៅលើអ្នកការពារសិទ្ធិមនុស្ស ទោះបីជាមិនមានតួលេខនៃករណីនេះ នៅក្នុងប្រទេសទាំងមូលក៏ដោយ ។

ប្រសិនបើគ្មានដំណោះស្រាយផ្នែកនយោបាយ ដើម្បីផ្លាស់ប្តូរចំណុចអវិជ្ជមាននៅក្នុងសង្គមសម្រាប់អ្នកទាំងនោះទេ សហគមន៍មូលដ្ឋាន កម្មករសហជីព និង សមាគមទាំងនេះ នឹងនៅតែបន្តធ្វើការរួមគ្នា ដើម្បីតស៊ូមតិសម្រាប់សិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួន ដែលជារឿយៗតែងតែប្រឈមមុខទៅនឹង អំពើហិង្សាពីសំណាក់អាជ្ញាធររដ្ឋ ។ របាយការណ៍នេះ ក៏បង្ហាញថាអ្នកការពារសិទ្ធិមនុស្ស និងក្រុមគ្រួសាររបស់អ្នកទាំងនោះ បានប្រឈមនឹងការគំរាមកំហែង ការវាយដំ និងវិធានការផ្លូវច្បាប់ ចំពោះភាពសកម្មរបស់ខ្លួន ។ អ្នកទាំងនោះជាច្រើនបានលះបង់ពេលវេលានៃជីវិតជាច្រើនឆ្នាំ នៅក្នុងពន្ធនាគារដែលមានសភាពចង្អៀតណែនខ្លាំង ។



កម្មករជាច្រើននាក់ទាមទារលក្ខខណ្ឌសុវត្ថិភាពការងារនៅ
ថ្ងៃទិវាពលកម្មអន្តរជាតិឆ្នាំ២០១៨នៅភ្នំពេញ

# ការដាក់កំហុសលើការជួបជុំគ្នា

នៅរយៈពេលជាងបីឆ្នាំកន្លងមកនេះ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការជួបជុំគ្នាដោយសេរី ដើម្បីលើកកម្ពស់សិទ្ធិជាមូលដ្ឋានរបស់ខ្លួន ត្រូវបានរឹតត្បិតយ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាល ដើម្បីរឹតត្បិតរាល់ការប្រមូលផ្ដុំគ្នា ។ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពនេះ អាជ្ញាធរបានប្រើប្រាស់ច្បាប់ស្ដីពីសហជីព ច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានលក្ខណៈរឹតត្បិត ដើម្បីអូសទាញអ្នករៀបចំព្រឹត្តិការណ៍ឱ្យអនុវត្តតាមច្បាប់នេះ តាមដានដោយឥតឈប់ឈរនូវក្រុមយុវជន សិស្ស-និស្សិត និងសកម្មជនបរិស្ថានដែលព្យាយាមរៀបចំយុទ្ធនាការសង្គមដោយអហិង្សា និងចូលរួមក្នុងយុទ្ធនាការបែបអវិជ្ជមាន ដើម្បីលាបពណ៌អង្គការសង្គមស៊ីវិលថាជាការរួមគំនិតនៃ "បដិវត្តន៍ពណ៌" ដែលសាធារណជនយល់ថាមានលក្ខណៈប្រឌិត ។

កាលពីខែមេសា ឆ្នាំ២០១៨ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្ដីការគណៈរដ្ឋមន្ត្រី បានចេញផ្សាយវីដេអូមួយដោយចោទប្រកាន់សមាជិកក្រុមមូលដ្ឋានឯករាជ្យមួយចំនួន រួមមានលោក វន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) និងលោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) ពាក់ព័ន្ធនឹងការញុះញង់ ។ វីដេអូនេះ បានចោទប្រកាន់អ្នកទាំងបីថា ជាសមាជិកនៃទ្រឹស្ដីរួមគំនិតធ្វើ "បដិវត្តន៍ពណ៌" ដែលមានលក្ខណៈទូលំទូលាយ និងគ្មានអត្ថន័យច្បាស់លាស់ ហើយក៏ជាទ្រឹស្ដីដែលក្រោយមកត្រូវបានផ្សព្វផ្សាយដដែលៗនៅក្នុងអត្ថបទព័ត៌មាន Fresh News របស់រាជរដ្ឋាភិបាល ។ អ្នកឃ្លាំមើលសិទ្ធិមនុស្ស ក៏ដូចជាមេធាវីដែលផ្ដល់ជំនួយផ្នែកច្បាប់ដល់អ្នក ដែលរងការចោទប្រកាន់ពីសំណាក់រាជរដ្ឋាភិបាល គឺតែងតែត្រូវបានចោទប្រកាន់នៃអំពើញុះញង់ឱ្យមានភាពវឹកវរនៅក្នុងសង្គម ដែលជាមធ្យោបាយមួយក្នុងការធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋមិនស្របច្បាប់ ។

ជាពិសេស ការធ្វើទុក្ខបុកម្នេញលើអ្នកការពារសិទ្ធិមនុស្ស ក៏កើតមានឡើងផងដែរចំពោះសហជីព និងអ្នកដែលជួយរៀបចំកម្មករ-កម្មការិនី ឱ្យតស៊ូមតិ ដើម្បីទទួលបានសិទ្ធិរបស់ពួកគេ ។ ក្នុងខែមករា ឆ្នាំ២០២០ លោក សុខ គីន ប្រធានសម្ព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) ត្រូវបានធ្វើទុក្ខបុកម្នេញដោយអាជ្ញាធរមូលដ្ឋាន ខណ្ឌសែនសុខនៃរាជធានីភ្នំពេញ ខណៈពេល ដែលលោកកំពុងជួបប្រជុំជាមួយម្ចាស់ជំនួយ និងសហការីនៅការិយាល័យក្នុងរាជធានីភ្នំពេញ ។ អាជ្ញាធរបានសួរពីគោលបំណងនៃការប្រជុំ ដោយចោទប្រកាន់លោក សុខ គីន ថាមិនបានសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំការប្រជុំជាលក្ខណៈឯកជននោះទេ ។ លោកលើកឡើងថា លោកត្រូវបានគេបញ្ចុះបញ្ចូលឱ្យចូលរួមជាមួយគណបក្សកាន់អំណាច ។

ការធ្វើទុក្ខបុកម្នេញលើមេដឹកនាំសហជីព និងសមាជិកសហជីពដែលគាំទ្រដល់កម្មករបែបនេះ ត្រូវបានផ្តល់ភាពស្របច្បាប់តាមរយៈច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ ដែលជាច្បាប់ទទួលរងការរិះគន់អស់រយៈពេលយូរណាស់មកហើយ និងត្រូវបានសាធារណមតិជាតិ និងអន្តរជាតិរិះគន់ថា បង្កើននូវការិយាធិបតេយ្យយ៉ាងច្រើនដល់សហជីព និងសហព័ន្ធសហជីពជាច្រើនក្នុងប្រទេស ។ សហជីពជាច្រើនបានរាយការណ៍ថា មានលក្ខខណ្ឌតម្រូវជាច្រើនលើសលប់ ដើម្បីធ្វើការចុះបញ្ជី ដែលនេះមានន័យថាដំណើរការចុះបញ្ជី ពេលខ្លះត្រូវចំណាយពេលជាងមួយឆ្នាំ ដោយធ្វើឱ្យសមត្ថភាពរបស់អ្នកទាំងនោះមានកម្រិតយ៉ាងខ្លាំង ក្នុងការតំណាងឱ្យសមាជិករបស់ពួកគេ ។ សហជីពជាច្រើនតែងតែប្រឈមមុខនឹងការបដិសេធក្នុងការទទួលបានការចុះបញ្ជី ដោយសំអាងលើមូលហេតុមួយចំនួនដែលមិនសមហេតុផល ដូចជាកំហុសអក្ខរាវិរុទ្ធ ។

ពេលខ្លះ ការគាបសង្កត់លើសមាជិកក្រុមមូលដ្ឋាន និងអ្នកដឹកនាំរបស់អ្នកទាំងនោះ ក៏រួមមានការប្រើប្រាស់អំពើហិង្សាយ៉ាងអាក្រក់ផងដែរ ។ កាលពីខែកុម្ភៈ ឆ្នាំ២០២០ លោក សឿង ប្រុស អនុប្រធានសហជីពនៃរោងចក្រកាត់ដេរ W&D Cambodia Co., LTD បានរងរបួសធ្ងន់ធ្ងរ បន្ទាប់ពីបុរសពាក់ម៉ាស់បិទមុខបីនាក់ជិះម៉ូតូមួយគ្រឿង បានយកដែកបំពង់ទីពមកវាយក្បាលរបស់លោក ខណៈពេលដែលលោកកំពុងឈរតម្រង់ជួរ ទិញម្ហូបនៅខាងក្រៅរោងចក្រដែលលោកធ្វើការក្នុងរាជធានីភ្នំពេញ ។ មិនមានជនសង្ស័យណាម្នាក់ ត្រូវបានចាប់ខ្លួននោះទេ ។ ចាប់តាំងពីពេលនោះមក មនុស្សជាច្រើននាក់ផ្សេងទៀតដែលពាក់ព័ន្ធនឹងសហជីព ឬអតីតគណបក្សជំទាស់ ដែលចូលរួមក្នុងការប្រមូលផ្តុំគ្នានៅទីសាធារណៈ បានរងអំពើហិង្សាស្រដៀងគ្នានេះ ។

សមាជិកបួននាក់នៃសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) និងបុគ្គលិកម្នាក់នៃគណកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានតុលាការផ្តន្ទាទោសពន្ធនាគាររយៈពេល ៥ឆ្នាំ ពីបទល្មើសសូកប៉ាន់សាក្សី កាលពីខែកញ្ញា ឆ្នាំ២០១៨ នៅក្នុងសវនាការរយៈពេលមួយថ្ងៃ បន្ទាប់ពីអ្នកទាំងប្រាំ បានជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការរយៈពេល ៤២៧ ថ្ងៃ ។ ទោះបីជាទោសនៅសល់ត្រូវបានព្យួរ ទោសពន្ធនាគារដែលមានលក្ខណៈនយោបាយនេះ នៅតែអាចត្រូវបានអនុវត្តលើអ្នកទាំងនោះវិញបានគ្រប់ពេល ។

សូម្បីតែការរៀបចំការរំលឹកដល់អ្នកដឹកនាំសង្គមស៊ីវិល ដែលបានលះបង់ជីវិត ក្នុងការកសាងទំនាក់ទំនងរួមគ្នារវាងសហគមន៍ផ្សេងៗជាច្រើន ក៏ត្រូវបានបង្ក្រាប ។ កាលពីខែកក្កដា ឆ្នាំ២០១៩ សកម្មជន គង់ រ៉ៃយ៉ា អាយុ ២៨ឆ្នាំ ត្រូវបានចាប់ខ្លួន បន្ទាប់ពីផ្សព្វផ្សាយនៅលើបណ្តាញសង្គមហ្វេសប៊ុក នូវអាវយឺតដែលមានរូបលោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយដែលត្រូវបានឃាតករបាញ់សម្លាប់ ។ ក្រោយមក លោក គង់ រ៉ៃយ៉ា ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍ ។ នៅថ្ងៃបន្ទាប់ សកម្មជនបរិស្ថានពីរនាក់ទៀតគឺ លោក ជុំ ហួត និងលោក ជុំ ហួរ ត្រូវបានចាប់ខ្លួនរួមជាមួយលោក សួង នាគព័ន្ធ អនុប្រធានក្រុមយុវជនសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA) ។ យុវជនទាំងបីនាក់នេះ បានចូលរួមជាមួយសកម្មជនជាយុវជន ប្រធានសហជីព និងសមាជិកសង្គមស៊ីវិលផ្សេងទៀត ដើម្បីគោរពវិញ្ញាណក្ខន្ធនៃការរំលឹកខួបបីឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី នៅទីតាំងដែលលោកត្រូវបានបាញ់សម្លាប់ក្នុងរាជធានីភ្នំពេញ ។ លោក នាគព័ន្ធ ក៏ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ទោះបីជាបទល្មើសដែលត្រូវបានចោទមកលើរូបលោក កើតឡើងដោយគ្រាន់តែលោកចែកខិតប័ណ្ណផ្សព្វផ្សាយ អំពាវនាវឱ្យបញ្ឈប់ការសម្លាប់មនុស្សក្រៅប្រព័ន្ធច្បាប់ ។ ទាំងលោក សួង នាគព័ន្ធ និងលោក គង់ រ៉ៃយ៉ា ត្រូវបានដោះលែងឱ្យនៅក្រៅឃុំវិញនៅឆ្នាំ ២០២០ ។ ក្រោយមក លោក គង់ រ៉ៃយ៉ា ត្រូវបានកាត់ទោសកំបាំងមុខ ក្នុងខែមិថុនា ។

## ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

ទោះបីជាមាន "កិច្ចប្រជុំពិភាក្សា" ជាច្រើនអំពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ចាប់តាំងពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២០នេះ គណបក្សកាន់អំណាចបានបង្ហាញយ៉ាងច្បាស់ថា រដ្ឋាភិបាលមិនទាន់មានឆន្ទៈ ដើម្បីធ្វើវិសោធនកម្មចំណុចមួយចំនួន នៃច្បាប់ដែលគ្រោះថ្នាក់មួយនេះនៅឡើយ ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលបានប្រើប្រាស់ច្បាប់នេះនៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីរារាំងសកម្មភាពអ្នកការពារសិទ្ធិមនុស្ស ជាពិសេសប្រជាពលរដ្ឋមកពីសហគមន៍មូលដ្ឋាននានា ។ ការធ្វើទុក្ខបុកម្នេញនេះបានកើនឡើង ទោះបីជាមានអង្គការសង្គមស៊ីវិលជាង ១០០ស្ថាប័ន ក៏ដូចជាសម្ព័ន្ធម៉ាកសំលៀកបំពាក់អន្តរជាតិ ដែលទិញពីកម្ពុជា បានជំរុញឱ្យរាជរដ្ឋាភិបាល លុបចោលច្បាប់ ដែលមានភាពចម្រូងចម្រាសនេះចោលវិញ ក្នុងឆ្នាំ២០២០ ។ នៅរយៈពេលជាងបីឆ្នាំកន្លងមកនេះ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានយកមកអនុវត្តម្តងហើយម្តងទៀត ដើម្បីផ្តល់ភាពស្របច្បាប់ដល់សកម្មភាពតាមដាន និងការបំភិតបំភ័យលើអង្គការសង្គមស៊ីវិល ដែលព្យាយាមធ្វើការជាមួយសហគមន៍មូលដ្ឋាន នៅតាមបណ្តាខេត្តនានាក្នុងប្រទេស ។

ក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលបានចោទប្រកាន់សហគមន៍មូលដ្ឋានជាច្រើនថា បានចូលរួមក្នុងសកម្មភាពខុសច្បាប់ ដោយមិនបានចុះបញ្ជីការនៅក្រសួងមហាផ្ទៃ រួមមាន បណ្តាញសហគមន៍ព្រៃឡង់ និងថ្មីៗនេះ សកម្មជនបរិស្ថាន និងយុវជន នៃក្រុមយុវជនមាតាធម្មជាតិ និងក្រុមយុវជនខ្មែរថាវរៈ ជាដើម ។ ការបង្ក្រាបជាថ្មីលើសកម្មជនមូលដ្ឋាន ដែលនាំឱ្យមានសកម្មជនជាយុវជនជាច្រើននាក់ជាប់ពន្ធនាគារ ក្រោយពីចូលរួមក្នុងការតវ៉ាដោយអហិង្សា គឺជាប្រើប្រាស់មិនត្រឹមត្រូវនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបង្ហាញពីភាពចាំបាច់ជាបន្ទាន់នៃការធ្វើនិរាករណ៍ច្បាប់ដែលមានគ្រោះថ្នាក់នេះចោលវិញ ។

## ករណីសិក្សា៖ លោក រ៉ុង ឈុន

លោក រ៉ុង ឈុន ប្រធានសហភាពសហជីពកម្ពុជា ត្រូវបានចាប់ខ្លួននៅផ្ទះរបស់លោកនៅពេលយប់ កាលពីចុងខែកក្កដា ឆ្នាំ២០២០ ។ លោក រ៉ុង ឈុន ជាអ្នកតស៊ូមតិដ៏ក្លាហានម្នាក់ក្នុងការការពារសិទ្ធិកម្មករនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ និងធ្លាប់ធ្វើជាប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ មុនពេលលោកក្លាយជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រហូតដល់ពេលរំលាយគណបក្សជំទាស់ ។ លោកត្រូវបានចាប់ខ្លួន បន្ទាប់ពីគណៈកម្មាធិការកិច្ចការព្រំដែនបានអំពាវនាវជាសាធារណៈ ឱ្យអាជ្ញាធរចាត់វិធានការលើរូបលោកជុំវិញការអត្ថាធិប្បាយរបស់លោក បន្ទាប់ពីលោកធ្វើទស្សនកិច្ចសិក្សានៅសហគមន៍ក្រីក្រ ដែលរស់នៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម កាលពីដើមខែកក្កដានោះ ។

លោក រ៉ុង ឈុន ដែលជាសមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាផងដែរនោះ បានផ្ដល់បទសម្ភាសជាមួយវិទ្យុមួយ នៅមុនពេលការចាប់ខ្លួនរបស់លោកប៉ុន្មានម៉ោង ដោយបានបដិសេធថា លោកមិនបានផ្សព្វផ្សាយព័ត៌មានមិនពិតនៅសប្ដាហ៍មុនពេលការចាប់ខ្លួនលោកនោះទេ ខណៈដែលលោកបានចេញផ្សាយសេចក្ដីថ្លែងការណ៍ជាសាធារណៈអំពីការចោទប្រកាន់ថាបាត់បង់ដីសហគមន៍នៅតាមបណ្ដោយព្រំដែន ។

ប្រធានសហជីពរូបនេះ ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ នៅមណ្ឌលអប់រំកែប្រែទី១ ក្នុងរាជធានីភ្នំពេញ រហូតមកដល់សព្វថ្ងៃនេះ ។ បទចោទដែលអាចឱ្យលោក រ៉ុង ឈុន ជាប់ពន្ធនាគាររហូតដល់ពីរឆ្នាំនេះ គឺជាការរំលោភបំពានយ៉ាងច្បាស់នៃសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់សហជីព ដែលបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

នៅមុនពេលការចាប់ខ្លួនលោកមួយសប្ដាហ៍ ប្រធានសហជីពរូបនេះ បានចូលរួមជាមួយកម្មករ-កម្មការិនីរោងចក្រកាត់ដេរជាង ២០០នាក់ ដែលបានជួបជុំគ្នា ដើម្បីដាក់ញត្តិនៅខាងក្រៅគេហដ្ឋានសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយស្នើសុំឱ្យសម្ដេចជួយអន្តរាគមន៍ចំពោះការបិទរោងចក្រ ដោយសារការរីករាលដាលជាសកលនៃជំងឺកូវីត១៩ ។ ដោយក្រោកឈរតស៊ូទាំងជាមួយកម្មករ-កម្មការិនីដើម្បីទាមទារសិទ្ធិរបស់ពួកគេនៅកន្លែងធ្វើការ និងទាំងសហគមន៍ដែលមិនត្រូវបានគេអើពើដើម្បីការពារសិទ្ធិដីធ្លី និងជីវភាពរស់នៅសមរម្យរបស់អ្នកទាំងនោះ លោក រ៉ុង ឈុន បានបង្ហាញថា ភាពជោគជ័យអាចកើតមានឡើងនៅពេលដែលមនុស្សជាច្រើនរួមសហការគ្នាដើម្បីសម្រេចគោលដៅរួមមួយ ។ បន្ទាប់ពីការចាប់ខ្លួនរបស់លោក អ្នកតវ៉ាដោយអហិង្សាជាង ១០នាក់ផ្សេងទៀត ដែលអំពាវនាវឱ្យមានការដោះលែងរូបលោកវិញ ក៏ត្រូវជាប់ពន្ធនាគារផងដែរ ។



ប្រធានសហជីព លោក រ៉ុង ឈុន ត្រូវបានចាប់ខ្លួនកាលពីខែ កក្កដា ឆ្នាំ២០២០បន្ទាប់ពីលោកបាននិយាយពីសហគមន៍ក្រីក្រដែលរស់នៅតាមបណ្ដោយព្រំដែនវៀតណាម




សកម្មជន យុវជនខ្មែរថាវរៈ ឈឿន ដារ៉ារី ត្រូវបានចាប់ខ្លួននៅខណៈពេលដែលធ្វើការតវ៉ាដោយអហិង្សា ដើម្បីអំពាវនាវឱ្យដោះលែងលោក រ៉ុង ឈុន

## *ករណីសិក្សា៖ ខ្មែរថាវរៈ*

*ដោយមើលឃើញឱកាសកាន់តែតិចទៅៗសម្រាប់យុវជនកម្ពុជាក្នុងការចូលរួមជីវិតជាពលរដ្ឋនៅក្នុងប្រទេសជាតិរបស់ខ្លួន នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះឃើញមានក្រុមយុវជន និងសិស្ស-និស្សិតជាច្រើន ដើរតួយ៉ាងសកម្ម ដើម្បីទាមទារឱ្យមានសង្គមកម្ពុជាមួយដែលមានភាពយុត្តិធម៌ និងសមភាព ។ ឆ្លើយតបនឹងសេចក្ដីក្លាហាន និងភាពជឿជាក់របស់ពួកគេ យុវជនយុវតីជាច្រើនបានប្រឈមនឹងការគំរាមកំហែង ការចាប់ខ្លួន និងការជាប់ពន្ធនាគារ ។*

*ទោះបីជាក្រុមយុវជនខ្មែរថាវរៈដែលទើបត្រូវបានបង្កើតឡើង បានជួបបញ្ហាជាមួយនគរបាលស្រាប់ហើយក្ដី ជាពិសេសនៅក្នុងការតវ៉ាដោយអហិង្សានៅដើមឆ្នាំនេះ នៅភាគពាយព្យនៃប្រទេស ក្នុងខេត្តបាត់ដំបង ដោយស្នើសុំឱ្យមានដំណោះស្រាយលើវិបត្តិបំណុលវ័ណ្ឌក ក្រុមយុវជនខ្មែរថាវរៈត្រូវបានចាប់ខ្លួនលើកដំបូង មុនពេលមានការចាប់ខ្លួនលោក រ៉ុង ឈុន ប្រធានសហជីព ។*

*បន្ទាប់ពីចូលរួមក្នុងការតវ៉ាដោយអហិង្សាមួយថ្ងៃនៅក្នុងរាជធានីភ្នំពេញ កាលពីខែសីហា ដើម្បីអំពាវនាវឱ្យដោះលែងលោក រ៉ុង ឈុន យុវតីសកម្មជនខ្មែរថាវរៈ ឈឿន ដារ៉ារី ត្រូវបានចាប់បោចសក់ចូលក្នុងរថយន្តដោយបុរសស្លៀកពាក់ស៊ីវិល បន្ទាប់ពីកាបូបលុយរបស់នាងត្រូវបានឆក់យកពីសំណាក់ក្រុមសន្តិសុខខណ្ឌនៅអំឡុងពេលតវ៉ា ។ ក្រោយមក សកម្មជនដៃគូរបស់នាងគឺលោក ហ៊ិន វណ្ណៈ ត្រូវបានមន្ត្រីស្លៀកពាក់ស៊ីវិលចាប់ខ្លួននៅថ្ងៃដដែលនោះ នៅខណៈពេលដែលលោកកំពុងដើរទៅផ្ទះបណ្ដើរ និងផ្សាយព័ត៌មានលើបណ្ដាញសង្គមបណ្ដើរ បន្ទាប់ពីការតវ៉ា ។*

*នៅថ្ងៃបន្ទាប់ សមាជិកក្រុមយុវជនម្នាក់ទៀតគឺលោក ថា ឡាវី អាយុ ១៩ឆ្នាំ ត្រូវបានចាប់ខ្លួន ខណៈពេល ដែល ចុះពីម៉ូតូកង់ បី នៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងចូលរួមក្នុងការតវ៉ាដោយសន្តិវិធីនៅទីតាំងធ្វើបាតុកម្មដែលត្រូវបានកំណត់ទុកមួយនេះ ។ លោកបានគ្រោងថានឹងអំពាវនាវឱ្យមានការដោះលែងសកម្មជនរួមក្រុមរបស់លោកវិញ ។ សមាជិកខ្មែរថាវរៈម្នាក់ទៀតគឺ កញ្ញា អេង ម៉ាឡៃ ត្រូវបានតាមដានដោយនគរបាលពីទីតាំងតវ៉ា និងត្រូវបានចាប់ខ្លួន ភ្លាមៗបន្ទាប់ពីចាកចេញពីការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស (UNOHCHR) ក្នុងរាជធានីភ្នំពេញ នៅល្ងាចថ្ងៃដដែលនោះ ។*

*ការបង្ក្រាបលើយុវជនដែលមានឆន្ទៈតស៊ូមតិទាមទារឱ្យមានសេរីភាព និងសមភាពនៅក្នុងសង្គម ដោយប្រើប្រាស់ការចាប់ខ្លួនបែបហិង្សា និងការគំរាមកំហែងនៃការចាប់ខ្លួនដាក់ពន្ធនាគារជាច្រើនឆ្នាំ អាចជាការប៉ុនប៉ងបំផ្លាញក្ដីស្រម៉ៃ ដែលថា ថ្ងៃស្អែកអាចនឹងប្រសើរជាងថ្ងៃនេះ ។ ការរំលោភបំពានដោយមិនត្រឹមត្រូវនៃសិទ្ធិក្នុងការជួបជុំ និងប្រមូលផ្ដុំគ្នារបស់យុវជនទាំងនេះ ត្រូវបានសាធារណជនយល់ថា ជាឧទាហរណ៍យ៉ាងច្បាស់នៃលំហការងារ ដែលនៅសល់ក្នុងប្រទេស សម្រាប់ការតស៊ូមតិជាសាធារណៈ ។*



សមាជិកបណ្ដាញសហគមន៍ព្រៃឡង់ជួបជុំគ្នា ដែលមានការឃ្លាំមើលពីមន្ត្រីឧទ្យាននុរក្សប្រដាប់ដោយអាវុធក្នុងពិធីបុណ្យបំបួសដើមឈើឆ្នាំ ២០១៩

# ការចេញតវ៉ាតាមដងផ្លូវ

សិទ្ធិសេរីភាពក្នុងជួបគ្នាតវ៉ាដោយសន្តិវិធីគឺជា សិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ ។ ប៉ុន្តែទោះបីជារាជរដ្ឋាភិបាលព្យាយាមរឹតត្បិតសិទ្ធិនេះដោយប្រើប្រាស់ហេតុផល ដែលគ្មានមូលដ្ឋានច្បាស់លាស់ និងការចោទប្រកាន់មិនត្រឹមត្រូវ ពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ក្ដី បុរសស្ត្រី និងក្មេងៗជាច្រើន ដែលបានចេញតវ៉ាដោយសន្តិវិធីនៅតាមដងផ្លូវក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ បានដឹងយ៉ាងច្បាស់ពីហានិភ័យនៃការជាប់ពន្ធនាគារ ដើម្បីការពារសិទ្ធិជាមូលដ្ឋាននេះ ដែលមានសារៈសំខាន់សម្រាប់ពួកគេ ក្នុងការត្រួសត្រាយផ្លូវដើរទៅមុខក្នុងកម្រិតមូលដ្ឋាន ។

សម្រាប់សហគមន៍កសិករ និងសហគមន៍ក្រីក្រមួយចំនួនដែលជាជនរងគ្រោះនៃការរំលោភយកដីធ្លីដោយហិង្សា និងការបណ្ដេញចេញដោយបង្ខំ ការប្រមូលផ្ដុំគ្នានៅខាងមុខសាលាខេត្តឬក្រុង អាចជាមធ្យោបាយដ៏មានឥទ្ធិពលមួយ ដើម្បីធ្វើឱ្យសំឡេងរបស់ពួកគាត់បានឮដល់អ្នកដទៃ ។ ប៉ុន្តែសហគមន៍ទាំងនេះបានប្រឈមនឹងការកើនឡើងនៃការតាមដានត្រួតពិនិត្យ និងការធ្វើទុក្ខបុកម្នេញពីសំណាក់អាជ្ញាធរមូលដ្ឋាន នៅពេលពួកគាត់ធ្វើសកម្មភាពដោយសន្តិវិធី ។ នៅថ្ងៃប្រារព្ធទិវាសិទ្ធិលំនៅឋានពិភពលោក ប្រជាពលរដ្ឋជាង ១០ សហគមន៍នៅទូទាំងប្រទេស បានប្រឈមនឹងការបំភិតបំភ័យ ពេលដែលពួកគាត់ព្យាយាមរៀបចំ ការជួបជុំគ្នាដោយសន្តិវិធី ។ ការរឹតត្បិតទាំងនេះបានធ្វើឱ្យសហគមន៍កាន់តែច្រើនឡើងៗ សម្រេចចិត្តរៀបចំទិវានេះ និងធ្វើការតស៊ូមតិតាមប្រព័ន្ធផ្សព្វផ្សាយសង្គមវិញ ដែលជាមធ្យោបាយមួយក្នុងការចែកចាយសាររបស់ពួកគេ ក្នុងពេលប្រឈមនឹងការគាបសង្កត់សេរីភាពក្នុងការជួបជុំគ្នា ។

ទោះបីជាទទួលបានព្រះរាជទាន លើកលែងទោសកាលពីខែសីហា ឆ្នាំ២០១៨ ក៏ដោយ ក៏អ្នកស្រី ទេព វន្នី សកម្មជនសិទ្ធិដីធ្លីតំបន់បឹងកក់ បានចំណាយពេលអស់ជាង ៧០០ថ្ងៃ នៅក្នុងពន្ធនាគារ ក្រោមបទចោទប្រកាន់ ដែលមានលក្ខណៈនយោបាយ ពីបទហិង្សាដោយចេតនា ក្រោយពីអ្នកស្រីបានចូលរួមការតវ៉ាដោយអហិង្សានៅឆ្នាំ ២០១៣ ។ អ្នកស្រីត្រូវបានតុលាការកំពូលសម្រេចតំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ កាលពីខែកុម្ភៈ ឆ្នាំ ២០១៨ ។ អ្នកស្រីបានរត់គៀសខ្លួនពីប្រទេសភ្លាមៗក្រោយពេលដែលអ្នកស្រីត្រូវបានតុលាការដោះលែង ។

កាលពីខែមិថុនា ឆ្នាំ២០២០ នគរបាលខេត្តកោះកុងបានបញ្ឈប់ដោយបង្ខំនូវសកម្មជនវ័យក្មេងមួយក្រុម ដែលព្យាយាមជិះកង់ពីសាលាខេត្តកោះកុង ឆ្ពោះទៅរាជធានីភ្នំពេញ ក្នុងយុទ្ធនាការបរិស្ថានមួយឈ្មោះថា "សង្គ្រោះកោះកុងក្រៅ" ។ នគរបាលខេត្តបានដកហូតកង់របស់យុវជនវ័យក្មេងទាំងនោះ ដើម្បីហាមឃាត់មិនឱ្យពួកគេបន្តដំណើរមកភ្នំពេញ ដាក់ញត្តិអំពាវនាវឱ្យមានការដាក់កោះធំជាងគេរបស់កម្ពុជាមួយនេះ ជាតំបន់ឧទ្យានជាតិ ។ កាលពីដើមខែឧសភា ក្រុមនគរបាលប្រដាប់ដោយកាំភ្លើង បានបំបែកបាតុកម្មអហិង្សាមួយ នៅខណ្ឌជ្រោយចង្វារក្នុងរាជធានីភ្នំពេញ ដោយបានដកហូតយកបដា និងទង់ជាតិដែលអំពាវនាវមានការការពារកោះកុងក្រៅ ព្រមទាំងបានគំរាមចាប់អ្នកចូលរួមទាំងនោះដាក់ក្នុងពន្ធនាគារផងដែរ ។

សម្រាប់អ្នកដែលប្រថុយជីវិត និងបាត់បង់ជីវភាព ដើម្បីឃ្លាំមើល និងបញ្ឈប់ការរកស៊ីកាប់បំផ្លាញព្រៃឈើខុសច្បាប់ដែលកើតមានឥតឈប់ឈរនៅកម្ពុជា ការរួមសហការគ្នាដើម្បីការពារព្រៃឈើដែលពួកគាត់តែងហៅថាផ្ទះ ជារឿយៗត្រូវបានបដិសេធផងដែរ ។ កាលពីខែកុម្ភៈ ឆ្នាំ២០២០ ប្រជាពលរដ្ឋជាង ២០០នាក់ ក្នុងនោះមានព្រះសង្ឃ សមាជិកសហគមន៍ និងសកម្មជនបរិស្ថានមកពីបណ្ដាញសហគមន៍ព្រៃឡង់ ត្រូវបានហាមឃាត់ដោយមន្ត្រីបរិស្ថាន និងនគរបាលប្រដាប់ដោយកាំភ្លើង នៅពេលដែលពួកគាត់ធ្វើដំណើរមកពីខេត្តផ្សេងៗចំនួន៥ ដើម្បីរៀបចំពិធីបុណ្យបំបួសព្រៃឡង់ ។ តំណាងសហគមន៍ចំនួន២រូប ត្រូវបានទទួលរងអំពើហិង្សាលើរូបរាងកាយ និងការគំរាមចាប់ខ្លួនពីសំណាក់មន្ត្រីបរិស្ថានប្រសិនប្រើពួកគាត់នៅតែបន្តដំណើរចូលទៅក្នុងព្រៃ ដើម្បីធ្វើពិធីបុណ្យនេះ ។

នេះមិនមែនជាលើកចុងក្រោយទេ ដែលមានការហាមឃាត់ក្នុងការធ្វើដំណើរចូលទៅព្រៃឡង់ សម្រាប់សហគមន៍ដែលបានខិតខំប្រឹងប្រែងក្នុងការអភិរក្សព្រៃមួយនេះ ។ កាលពីខែមេសា ឆ្នាំ២០២០ សកម្មជនបរិស្ថានរាប់សិបនាក់ ត្រូវបានហាមឃាត់មិនជួបជុំគ្នានៅក្នុងព្រៃឡង់ ដើម្បីធ្វើពិធីរំលឹកខួបនៃឃាតកម្មរបស់លោក ឈុត វុទ្ធី សកម្មជនបរិស្ថាននិងជាអ្នកការពារព្រៃកម្ពុជា ។ ជាថ្មីម្ដងទៀត សកម្មជនផ្សេងទៀតត្រូវបានប្រឈមជាមួយនឹងមន្ត្រីឧទ្យានុរក្ស និងត្រូវបានគំរាមចាប់ខ្លួនផងដែរ ។ កូនប្រុសលោក ឈុត វុទ្ធី ដែលពេលនេះជាប្រធានអង្គការការពារធនធានធម្មជាតិ គឺជាសកម្មជនវ័យក្មេងម្នាក់ក្នុងចំណោមអ្នកដទៃទៀត ដែលត្រូវបានហាមឃាត់ មិនឱ្យគោរពវិញ្ញាណក្ខន្ធឪពុករបស់លោកដែលត្រូវបានគេបាញ់សម្លាប់ ។ នៅថ្ងៃបន្ទាប់ មេបញ្ជាការយោធាម្នាក់បានបញ្ជូនទាហាន ៥០នាក់ ទៅក្នុងព្រៃ ដើម្បីស្វែងរកសកម្មជនបរិស្ថាន៥នាក់ ដែលជាការបង្ហាញកងកម្លាំងដោយឥតលាក់លៀមនៅចំពោះមុខសហគមន៍មូលដ្ឋាន ។



បណ្ដាញសហគមន៍ព្រៃឡង់បានប្ដេជ្ញាចិត្តក្នុងកិច្ចការពារព្រៃរបស់កម្ពុជាពីការកាប់បំផ្លាញព្រៃឈើដែលខុសច្បាប់

## ករណីសិក្សា៖ ក្រុមយុវជនមាតាធម្មជាតិ

ក្រោយពីក្រសួងមហាផ្ទៃបានលុបឈ្មោះចេញពីបញ្ជីការអង្គការមិនមែនរដ្ឋាភិបាលកាលពីខែកញ្ញា ឆ្នាំ២០១៧ ក្រុមយុវជនមាតាធម្មជាតិនៅតែបន្តសកម្មភាពជាក្រុមយុវជនការពារបរិស្ថាន ដែលលះបង់ក្នុងការបង្ហាញពីការបំផ្លិចបំផ្លាញបរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាប្រឈមទៅនឹងសម្ពាធពីសំណាក់អាជ្ញាធរមូលដ្ឋាននៅគ្រប់ជំហានក្តី ក៏ក្រុមយុវជននេះនៅតែបន្តដើរតួយ៉ាងសំខាន់ក្នុងការរក្សាកេរដំណែលរបស់ប្រជាពលរដ្ឋទាំងអស់គ្នា តាមរយៈការអភិរក្ស ការការពារ និងភាពសកម្មក្នុងកិច្ចការបរិស្ថាន ។ ប៉ុន្តែ្បិតតែមិនស្ថិតក្នុងរយៈពេលនៃរបាយការណ៍ កាលពីខែកញ្ញា ឆ្នាំ២០១៧ សកម្មជនបរិស្ថាន លោក ឌឹម គុនឌី និងលោក ហ៊ុន វណ្ណៈ ត្រូវបានចាប់ខ្លួន បន្ទាប់ពីបានថតយករូបភាពកប៉ាល់ដឹកទំនិញ ដែលត្រូវបានសង្ស័យថា កំពុងដឹកជញ្ជូនខ្សាច់ខុសច្បាប់ចេញនៅក្នុងខេត្តកោះកុង ។ នៅខែមករា ឆ្នាំ២០១៨ អ្នកទាំងពីរត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ ដោយ៧ខែនៃទោសត្រូវបានព្យួរ ។ អ្នកទាំងពីរបានចំណាយពេលជាច្រើននៅពេលស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ។ គិតត្រឹមពេលចេញផ្សាយរបាយការណ៍នេះ លោក ហ៊ុន វណ្ណៈ កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្នម្តងទៀត ដោយសារតែភាពសកម្មដោយសន្តិវិធីរបស់លោក ។

ជាថ្មីម្តងទៀត ចលនានេះត្រូវបានបង្ក្រាបម្តងទៀតក្នុងខែកញ្ញា ឆ្នាំ២០២០ នៅពេលដែលអាជ្ញាធរបានចោទប្រកាន់សកម្មជនបរិស្ថានវ័យក្មេង៣នាក់ពីបទញុះញង់ និងបានបញ្ជូនពួកគេទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ។ សកម្មជនទាំង៣នាក់ បានព្យាយាមស្វែងរកការចាប់អារម្មណ៍ពាក់ព័ន្ធនឹងសកម្មភាពលុបបឹងតាមោកនៅក្នុងរាជធានីភ្នំពេញពីសំណាក់រាជរដ្ឋាភិបាល ប៉ុន្តែការតវ៉ាដោយសន្តិវិធីរបស់ពួកគេ បានធ្វើឱ្យអាជ្ញាធរមិនពេញចិត្ត ។

សកម្មជនទាំង ៣នាក់គឺ លោក ថុន រដ្ឋា កញ្ញា ឡុង គន្ធា និងកញ្ញា ភួន កែវរស្មី ត្រូវបានចាប់ខ្លួន ពាក់ ព័ន្ធនឹងការរៀបចំការដង្ហែរក្បួនដោយសន្តិវិធីពីវត្តភ្នំ ឆ្ពោះទៅកាន់គេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ កញ្ញា គន្ធា បានគ្រោងថានឹងដើរដង្ហែក្បួនដើម្បីបង្ហាញពីកង្វល់របស់នាង ពាក់ព័ន្ធនឹងការពុះចែកដីបឹងធំជាងគេដែលនៅសល់ក្នុងរាជធានីភ្នំពេញ ទៅឱ្យបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកមានអំណាច ។ អ្នកទាំង៣ ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងកំពុងស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ។ ក្នុងចំណោមពួកគេទាំង៣នាក់ កញ្ញា ភួន កែវរស្មី មានវ័យក្មេងជាងគេ គឺទើបតែ ១៩ឆ្នាំ ប៉ុណ្ណោះ។

ដោយការអំពាវនាវឱ្យរក្សា និងការពារធនធានធម្មជាតិរបស់ប្រទេស ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់គ្នា និងកុំឱ្យលក់ឱ្យអ្នកមានទ្រព្យនិងអំណាច សកម្មជនការពារបរិស្ថានដូចជា លោក រដ្ឋា កញ្ញា គន្ធា និងកញ្ញា រស្មី បានលើកឡើងពីបញ្ហាសំខាន់មួយដែលទំនងជាអាចពណ៌នាពីស្ថានភាពនៃការអភិវឌ្ឍរាជធានីភ្នំពេញ នៅរយៈពេល ១ទសវត្សរ៍ទៀត ឬច្រើនជាងនេះ ។ កង្វល់របស់ពួកគេ គឺជាកង្វល់របស់ប្រជាពលរដ្ឋរាប់លាននាក់ ហើយការចាប់ខ្លួនរបស់ពួកគេ គឺជាវិធានការមិនសមស្រប ដើម្បីបង្ក្រាបការពិភាក្សាទៅលើប្រធានបទដែលមានសារៈសំខាន់ជាច្រើនសម្រាប់សាធារណៈជន ។



កញ្ញា ឡុង គន្ធា សកម្មជនមាតាធម្មជាតិ ត្រូវបានឃុំខ្លួននៅឆ្នាំ២០២០នេះ ដោយសារតែគ្រោងថានឹងដើរថ្មើរជើងម្នាក់ឯងក្នុងទីក្រុងភ្នំពេញ ដើម្បីតវ៉ារឿងការលុបបឹងតាមោក។



អ្នកភូមិក្នុងខេត្តត្បូងឃ្មុំធ្វើការឃាត់គ្រឿងចក្រមិនឱ្យឈូសឆាយដីស្រែចម្ការ និងផ្ទះរបស់ពួកគេ

## *ករណីសិក្សា៖ ក្រុមហ៊ុន ហាម៉ឺនី រីន អ៊ិនវេសមេន*

*នៅដើមខែធ្នូ ឆ្នាំ២០១៩ ប្រជាពលរដ្ឋជាង ១០០នាក់នៅខេត្តត្បូងឃ្មុំ បានជួបជុំគ្នាដើម្បីតវ៉ា ប្រឆាំងនឹងក្រុមហ៊ុនចិន ហាម៉ឺនី រីន អ៊ិនវេសមេន ដែលបានព្យាយាមឈូសឆាយដីស្រែរបស់ពួកគាត់ ដែលពួកគាត់ប្រើប្រាស់សម្រាប់ធ្វើស្រែបង្កបង្កើនផលស្រូវ ។ ក្រុមហ៊ុនឯកជនមួយនេះ បានយកគ្រឿងចក្រចំនួន ១០គ្រឿង ដើម្បីឈូសឆាយដីស្រែនោះ ដោយការយាមល្បាតពីសំណាក់ទាហានប្រហែល ៣០នាក់ និងនគរបាលដែលដើរតួជាសន្តិសុខ សម្រាប់ក្រុមហ៊ុន ។*

*ប្រជាពលរដ្ឋក្នុងសហគមន៍បានរងគ្រោះគ្រប់គ្រាន់ហើយសម្រាប់ភាពសកម្មរបស់ពួកគាត់ ។ មុនពេលកើតមានហេតុការណ៍នេះពីរខែ តំណាងសហគមន៍២នាក់ គឺលោក សែម សាង និងលោក ផុន ឈឿន ត្រូវបានចាប់ខ្លួន បន្ទាប់ពីអ្នកទាំងពីរព្យាយាមការពារសិទ្ធិទទួលបានដីធ្លី និងជីវភាពសមរម្យរបស់សហគមន៍ ។ សមាជិកសហគមន៍ផ្សេងទៀតដែលព្យាយាមធ្វើដំណើរទៅសាលាដំបូងខេត្តត្បូងឃ្មុំ ដើម្បីឃ្លាំមើលសវនាការកាលពីខែតុលា ឆ្នាំ២០១៩ ត្រូវបានហាមឃាត់នៅតាមដងផ្លូវ ដោយកងកម្លាំងចម្រុះ ។ អ្នកទាំងពីរ ត្រូវបដិសេធមិនឱ្យនៅក្រៅឃុំនោះទេកាលពីខែមករា ឆ្នាំ២០២០ ។ ក្រោយមក ឈឿន ត្រូវបានតុលាការដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នកាលពីខែមិថុនា រីឯ សាង នៅបន្តជាប់ឃុំខ្លួនបណ្ដោះអាសន្នមកដល់បច្ចុប្បន្ន ។*

*គិតត្រឹមខែមិថុនា សន្តិសុខរបស់ក្រុមហ៊ុន ហាម៉ឺនី រីន អ៊ិនវេសមេន បានបន្តបិទផ្លូវធ្វើដំណើររបស់សហគមន៍ចូលទៅដីស្រែចំការរបស់ពួកគាត់ ។ ប្រជាពលរដ្ឋជាង ៦០០គ្រួសារ ដែលពឹងផ្អែកលើដីសម្រាប់ស្នាក់អាស្រ័យ និងធ្វើស្រែចំការ ត្រូវបានរងផលប៉ះពាល់ដោយជម្លោះនេះ ។ ជម្លោះនេះនៅតែបន្តអូសបន្លាយដោយគ្មានដំណោះស្រាយអស់រយៈពេល ៨ឆ្នាំមកហើយ ។*



អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី លោក យាង សុធារិទ្ធ និងលោក អ៊ួន ឈិន ត្រូវបានដោះលែងឱ្យនៅក្រៅឃុំក្នុងឆ្នាំ ២០១៨ ។ ពួកគាត់ត្រូវបានគេដាក់ឱ្យស្ថិតនៅក្រោមការស៊ើបអង្កេតពីបទចារកម្ម ដែលមានលក្ខណៈជារឿងនយោបាយ ។

# សេរីភាពក្នុងការបញ្ចេញមតិ

ទោះបីជាមានការបិទ ឬផ្លាស់ប្តូរការគ្រប់គ្រងលើសារព័ត៌មានឯករាជ្យមួយចំនួននៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏អ្នកសារព័ត៌មានក្នុងស្រុកជាច្រើន នៅតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការលាតប្រដាងអំពើពុករលួយ និងវប្បធម៌និទណ្ឌភាពនៅក្នុងប្រទេសដដែល ។ អ្នកសារព័ត៌មានទាំងនេះ អាចប្រឈមនឹងគ្រោះថ្នាក់យ៉ាងខ្លាំង ដែលអាចជាហានិភ័យក្នុងការជាប់ពន្ធនាគារ នៅពេលដែលអ្នកទាំងនោះចេញផ្សាយនូវអត្ថបទព័ត៌មានរិះគន់ណាមួយ ។

នៅក្នុងអំឡុងពីឆ្នាំ ២០១៧ ដែលជាឆ្នាំនៃការបោះឆ្នោតឃុំសង្កាត់ ដល់ឆ្នាំ ២០១៨ ជាឆ្នាំនៃការបោះឆ្នោតថ្នាក់ជាតិ កាសែតខ្មែរប៉ូស្ដិ៍ដេលី (Cambodia Daily) ត្រូវបានបិទ ឯកាសែតភ្នំពេញប៉ុស្ដិ៍ (Phnom Penh Post) ត្រូវបានផ្លាស់ប្តូរអ្នកគ្រប់គ្រង ។ ស្ថាប័នសារព័ត៌មានទាំងពីរ ធ្លាប់ជាស្ថាប័នសារព័ត៌មានឯករាជ្យទ្វេភាសា (ភាសាខ្មែរ និងអង់គ្លេស) ដែលដំណើរការដោយអ្នកសារព័ត៌មានក្នុងស្រុក និងបរទេសជាច្រើន ។ ដោយប្រឈមមុខនឹងការបង់ពន្ធយ៉ាងច្រើនលើសលុប និងមិនត្រឹមត្រូវ កាសែតខេមបូឌាដេលី បានប្រកាសបិទទ្វារឈប់ដំណើរការ នៅខែកញ្ញា ឆ្នាំ២០១៧ ។ ចំណែកឯកាសែតភ្នំពេញប៉ុស្ដិ៍ ក៏ត្រូវបានគេគំរាមកំហែងថានឹងបង្ខំឱ្យបង់ពន្ធយ៉ាងច្រើនលើសលុបដូចគ្នា ។ ហើយនៅខែមេសា ឆ្នាំ២០១៨ កាសែតនេះក៏ត្រូវបានទិញយកដោយអ្នកជំនួញជនជាតិម៉ាឡេស៊ីម្នាក់ ដែលមានទំនាក់ទំនងជាមួយគណបក្សកាន់អំណាច ។ បន្ទាប់ពីការទិញយកកាសែតភ្នំពេញប៉ុស្ដិ៍នេះ អត្ថបទចេញផ្សាយមួយ ដែលបានស៊ើបអង្កេតលើទំនាក់ទំនងខាងលើ ទទួលបានប្រតិកម្មតបពីអ្នកគ្រប់គ្រងថ្មីនៃកាសែតនេះ ដោយបានបណ្តេញនិពន្ធនាយក និងអ្នកកាសែតដែលបានសរសេរអត្ថបទនេះ ចេញពីការងារ ។ ក្រោយពីមានការបណ្តេញចេញមក អ្នកពិនិត្យផ្ទៀងផ្ទាត់ និងអ្នកកាសែតជាច្រើននាក់ផ្សេងទៀត បានលាឈប់ពីការងារ ។

ការបិទសម្លេងសារព័ត៌មានទាំងពីរ និង ៣០ ស្ថានីយ៍វិទ្យុទៀត ដែលផ្សាយបន្តកម្មវិធីរបស់វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុអាស៊ីសេរី (RFA) នៅមុនពេលមានការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ គឺជាការកាត់ផ្តាច់ប្រភពព័ត៌មានសម្រាប់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ ។ អ្នកសារព័ត៌មាន ដែលបន្តធ្វើការងារផ្សព្វផ្សាយការពិត កាន់តែប្រឈមមុខនឹងការគំរាមកំហែង ទាំងផ្លូវកាយ និងផ្លូវច្បាប់ ។

អតីតអ្នកកាសែតវិទ្យុអាស៊ីសេរីពីររូប លោក អ៊ួន ឈិន និងលោក យាង សុធារិន្ទ នៅបន្តជាប់ក្នុងរឿងក្តីនៅតុលាការនៅឡើយ ក្រោយពេលតុលាការកំពូលសម្រេចបដិសេធសំណើសុំរបស់អ្នកទាំងពីរ ឱ្យបញ្ឈប់ការស៊ើបអង្កេតដែលគ្មានទីបញ្ចប់ទៅលើការប្រកាន់ដែលមានលក្ខណៈនយោបាយ ពីបទផ្តល់ព័ត៌មានឱ្យរដ្ឋបរទេសដែលអាចអន្តរាយដល់ការការពារជាតិ និងផលិតរូបអាសអាភាស កាលពីខែតុលា ឆ្នាំ២០២០ ។ អ្នកទាំងពីរត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និងត្រូវបានអាជ្ញាធរចាប់ដាក់ពន្ធនាគារបណ្តោះអាសន្ន រង់ចាំសវនាការអស់រយៈពេលជាង ៩ខែ មុនពេលត្រូវបានតុលាការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ។

នៅក្នុងខែឧសភា ឆ្នាំ២០២០ នគរបាលនៅក្នុងខេត្តកំពង់ឆ្នាំង បានចាប់ខ្លួនម្ចាស់ស្ថានីយវិទ្យុក្នុងស្រុកម្នាក់ឈ្មោះ សុខ ឧត្តម ដោយចោទប្រកាន់ពីបទ "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍" នៅពេលដែលលោកបានរាយការណ៍ព័ត៌មាន អំពីជម្លោះដីធ្លីរវាងសហគមន៍កសិករ និងអាជ្ញាធរស្រុក ។ មួយថ្ងៃមុនពេលដែលលោកឧត្តម ត្រូវបានគេចាប់ខ្លួន ក្រសួងព័ត៌មាន បានលុបចោលអាជ្ញាប័ណ្ណសារព័ត៌មាននៃស្ថានីយវិទ្យុ និងគេហទំព័ររីទ្ធីសែនរបស់លោក ទោះបីជាលោកមិនទាន់ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសណាមួយនៅឡើយក៏ដោយ ។ បច្ចុប្បន្នលោកកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ។

នៅក្នុងខែមិថុនា ឆ្នាំនេះ នគរបាលរាជធានីភ្នំពេញ បានចាប់ខ្លួនលោក រស់ សុឃិត អ្នកសារព័ត៌មាន និងចាងហ្វាងរបស់កាសែតជាតិខ្មែរ បន្ទាប់ពីលោកបានបង្ហោះសារជាច្រើន នៅលើគេហទំព័រហ្វេសប៊ុករបស់លោក ដោយលើកឡើងពីការដោះស្រាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើបញ្ហាបំណុលមីក្រូហិរញ្ញវត្ថុដែលកំពុងកើនឡើងនៅក្នុងប្រទេស និងការប្រមើលមើលជុំវិញការបន្តវេននយោបាយក្នុងជួរគណបក្សកាន់អំណាច ។ ដូចករណីខាងលើដែរ លោកត្រូវបានតុលាការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដោយសារលោកបានបញ្ចេញមតិទាក់ទងនឹងប្រយោជន៍សាធារណៈ ហើយលោកត្រូវបានតុលាការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅពន្ធនាគារព្រៃស រាជធានីភ្នំពេញ ។ លោកត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១៨ ខែ កាលពីខែវិច្ឆិកា ។

បទចោទប្រកាន់នេះត្រូវបានប្រើប្រាស់ចំពោះការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្សនានា ដែលហាក់ដូចជាការរាយការណ៍ទាំងនោះ ជាការញុះញង់ឱ្យសាធារណៈជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ ការចោទប្រកាន់ខាងលើនេះ ត្រូវបានគេប្រើប្រាស់កាន់តែញឹកញាប់ ដោយមិនត្រឹមតែទៅលើអ្នកកាសែតប៉ុណ្ណោះទេ ថែមទាំងទៅលើអង្គការសង្គមស៊ីវិលជាច្រើនដែលឃ្លាំមើលការរំលោភបំពានទាំងនោះនៅទូទាំងប្រទេស ។



អតីតនិពន្ធនាយកកាសែតភ្នំពេញប៉ុស្តិ៍ លោក កែ គឹមសុង ឱបជាគ្នាមួយអ្នកសារព័ត៌មានផ្សេងទៀត បន្ទាប់ពីលោកត្រូវបានអ្នកគ្រប់គ្រងថ្មីបណ្តេញចេញពីការងារ

## ករណីសិក្សា៖ សុវណ្ណរិទ្ធី

នៅដើមឆ្នាំ ២០២០ ប្រទេសកម្ពុជាបានជួបប្រទះបញ្ហាផ្នែកសេដ្ឋកិច្ច និងប្រព័ន្ធសុខភាពសាធារណៈ ក្រោយពេលដែលមានការរាយការណ៍អំពីការឆ្លងរីករាលដាលនៃមេរោគ កូវីដ ១៩ នៅក្នុងប្រទេសជាលើកដំបូងមក ។ តម្រូវការសារព័ត៌មានឯករាជ្យក្នុងវេលានេះ ដើម្បីឱ្យពលរដ្ឋដែលកំពុងភិតភ័យពីការឆ្លងជំងឺទទួលបាននូវព័ត៌មាន គឺកាន់តែមានសារៈសំខាន់ខ្លាំងឡើង ។ ផ្ទុយទៅវិញ អាជ្ញាធរបែរជាចាប់ខ្លួនអ្នកកាសែតដ៏មានប្រជាប្រិយម្នាក់ គឺលោក សុវណ្ណរិទ្ធី ក្រោយពេលដែលលោកបានផ្សព្វផ្សាយបន្តនូវអ្វីដែលសម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ ដើម្បីជួយដល់ពលរដ្ឋអំឡុងពេលវិបត្តិសេដ្ឋកិច្ច និងការរីករាលដាលនៃមេរោគ កូវីដ ១៩ ។

អំឡុងពេលសុន្ទរកថាជាសាធារណៈកាលពីខែមេសា សម្តេចនាយករដ្ឋមន្ត្រី បានលើកឡើងម្តងហើយម្តងទៀតថារាជរដ្ឋាភិបាលមិនមានកញ្ចប់ថវិកាគ្រប់គ្រាន់ ដើម្បីជួយដល់កម្មករក្នុងវិស័យក្រៅប្រព័ន្ធ ដូចជាអ្នករត់ម៉ូតូឌុបនោះទេ អំឡុងពេលវិបត្តិសេដ្ឋកិច្ចដែលបង្កដោយការឆ្លងនៃមេរោគ កូវីដ ១៩ ហើយឱ្យយោបល់ថាអ្នករត់ម៉ូតូឌុបទាំងនោះ គួរតែលក់ម៉ូតូរបស់ខ្លួនដើម្បីទ្រទ្រង់ជីវភាពបណ្តោះអាសន្នសិនទៅ ។

ក្រោយពេលដែលលោក រិទ្ធី បង្ហោះសារលើបណ្តាញសង្គមរបស់ខ្លួន ដោយដកស្រង់ប្រសាសន៍របស់សម្តេចខាងលើ លោកត្រូវបានអាជ្ញាធរចាប់ខ្លួនទាំងយប់ និងចោទប្រកាន់ពីបទ "ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍" ។ សារព័ត៌មានរបស់លោកក៏ត្រូវបានក្រសួងដកអាជ្ញាប័ណ្ណ មួយថ្ងៃក្រោយការចាប់ខ្លួនរបស់លោក ។ លោកត្រូវបានតុលាការផ្តន្ទាទោសកាលពីខែតុលា ដោយត្រូវជាប់ពន្ធនាគារចំនួន ១៨ខែ ប៉ុន្តែទោសដែលនៅសល់ត្រូវព្យួរ ។ មុនពេលផ្តន្ទាទោស លោកបានជាប់ពន្ធនាគារបណ្តោះអាសន្នរយៈពេលជាង ៥ខែមកហើយ ។ ទោះបីជាលោកត្រូវបានតុលាការដោះលែងហើយក៏ដោយ ក៏លោកអាចនឹងត្រូវតុលាការចាប់មកអនុវត្តទោសដែលត្រូវបានព្យួរវិញ ប្រសិនបើរកឃើញកំហុស ។ ស្ថានីយទូរទស្សន៍អនឡាញរបស់លោក ក៏មិនត្រូវបានក្រសួងផ្តល់អាជ្ញាប័ណ្ណវិញនោះទេ ។




អ្នកកាសែត TVFB លោកសុវណ្ណ រិទ្ធី គឺជាអ្នកកាសែតម្នាក់ក្នុងចំណោមអ្នកកាសែតផ្សេងទៀត ដែលត្រូវបានរដ្ឋាភិបាលតាមដានពីការរាយការណ៍ព័ត៌មានរបស់គាត់
រូបភាពដោយ ខេមបូចា



សកម្មជនសង្ឃ ព្រះតេជគុណ លួង សុវាត ដែលធ្លាប់រងការវាយប្រហារពីរាជរដ្ឋាភិបាលក្នុងការការពារសិទ្ធិមនុស្សរបស់ព្រះអង្គ

## ករណីសិក្សា៖ ព្រះតេជគុណ លួន សុវាត

ព្រះតេជគុណ លួន សុវាត គឺជាសកម្មជនសង្ឃដ៏លេចធ្លោមួយអង្គ និងជាអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ នៅពេលដែលព្រះអង្គចេញព្រះកាយផ្សព្វផ្សាយអំពីជម្លោះដីធ្លីនៅក្នុងតំបន់បឹងកក់ ។ ចាប់តាំងពីពេលនោះមក ព្រះអង្គបានលះបង់ព្រះកាយពលឥតឈប់ឈរ ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋទូទៅ ទោះបីជាព្រះអង្គក្លាយជាគោលដៅដែលត្រូវបានគេមួលបង្កាច់ និងគំរាមហែងពីគណបក្សកាន់អំណាចអស់រយៈពេលជាច្រើនឆ្នាំមកហើយក៏ដោយ ។

នៅក្នុងឆ្នាំ ២០២០ យុទ្ធនាការនៃការបំភិតបំភ័យនេះ កាន់តែអាក្រក់ឡើង ដោយការផ្សព្វផ្សាយនូវសំឡេងលេចធ្លាយជាសាធារណៈ នៅលើបណ្តាញសង្គម កាលពីខែមិថុនា ដោយចោទប្រកាន់ព្រះតេជគុណថា បានល្មើសនឹងវិន័យព្រះសង្ឃ ។ ពីរបីខែក្រោយមក ការស៊ើបអង្កេតមួយ ត្រូវបានធ្វើឡើងដោយកាសែត ឌឹញូយកថែម (The New York Time) ដែលបានបង្ហាញថា មន្ត្រីនៅអង្គភាពប្រតិកម្មរហ័សនៃទីស្តីការគណរដ្ឋមន្ត្រី ដែលជាសេនាធិការផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាអ្នកបង្កើត និងបង្ហោះសារជាវីដេអូសំឡេងកាត់តនោះទៅលើបណ្តាញសង្គម ។

សម្រាប់ព្រះតេជគុណ លួន សុវាត ការបកអាក្រាតសកម្មភាពមួលបង្កាត់នេះ ហាក់រាងយឺតពេលបន្តិច ។ ព្រះអង្គ ត្រូវបានគណៈសង្ឃខេត្តសៀមរាប ផ្សឹកដោយមិនមានវត្តមានព្រះអង្គ ព្រោះព្រះអង្គបានភៀសព្រះកាយចាកចេញពីប្រទេស ហើយព្រះអង្គត្រូវបានគេចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ។

យុទ្ធនាការមួលបង្កាត់មកលើអ្នកការពារសិទ្ធិមនុស្សដោយមិនត្រឹមត្រូវនេះ មានគោលបំណងធ្វើឱ្យខូចកិត្តិយសព្រះអង្គ ជាអ្នកដែលតែងតែទាមទារឱ្យអាជ្ញាធររដ្ឋទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សនានាដែលអាជ្ញាធររដ្ឋបានប្រព្រឹត្តិ ។ សកម្មភាពទាំងនេះ ត្រូវបានគេប្រើប្រាស់ម្តងហើយម្តងទៀត មកលើព្រះសង្ឃដែលព្រះអង្គគ្រាន់តែប្រើប្រាស់សិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីចូលរួមដោយសេរីក្នុងការប្រមូលផ្តុំអហិង្សាក្នុងបុព្វហេតុសង្គមតែប៉ុណ្ណោះ ។ ព្រះសង្ឃបួនអង្គផ្សេងទៀតមកពីវត្តផ្សេងៗគ្នា ដែលបាននិមន្តចូលរួមការតវ៉ាដោយអហិង្សានៅខេត្តបាត់ដំបងកាលពីខែឧសភា ត្រូវបានគេគម្រាមកំហែងថានឹងបណ្តេញព្រះអង្គចេញពីវត្ត ដោយសារព្រះអង្គនិមន្តចូលរួមក្នុងការតវ៉ាអហិង្សានោះ ។ កាលពីខែវិច្ឆិកាឆ្នាំនេះ ព្រះសង្ឃពីរអង្គដែលគង់នៅវត្តក្នុងរាជធានីភ្នំពេញ បានភៀសព្រះកាយឆ្លងទៅប្រទេសថៃ ដោយសារព្រះអង្គបានទទួលដំណឹងថានគរបាលកំពុងស្វែងរកចាប់ព្រះកាយព្រះអង្គនៅក្នុងវត្ត និងនៅស្រុកកំណើត បន្ទាប់ពីព្រះអង្គបាននិមន្តចូលរួមក្នុងការតវ៉ាអហិង្សាស្នើសុំឱ្យដោះលែងលោក រ៉ុង ឈុន ។

ករណីព្រះអង្គ ក៏ដូចជាករណីព្រះសង្ឃជាច្រើនអង្គផ្សេងទៀត ដែលត្រូវបានចាប់ព្រះកាយ ចាប់ផ្សឹក ឬបង្ខំឱ្យភៀសព្រះកាយចេញពីប្រទេស គឺជារឿងគួរឱ្យសោកស្តាយយ៉ាងខ្លាំង ដោយសារការមិនលើកលែងរបស់អាជ្ញាធររដ្ឋក្នុងការបង្ក្រាបទៅលើភាពសកម្មនិយមផ្នែកសិទ្ធិមនុស្ស ទោះបីជាសកម្មជនទាំងនោះ ជាព្រះសង្ឃក៏ដោយ ។

## ការបង្កើនចំនួនច្បាប់ដែលមានលក្ខណៈរឹតត្បិត

គណបក្សកាន់អំណាច បានប្រើប្រាស់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីអនុម័ត ឬរៀបចំនូវច្បាប់ជាច្រើន ដែលបានផ្តល់អំណាចស្ទើរតែគ្មានដែនកំណត់ទៅរាជរដ្ឋាភិបាល ក្នុងការចាប់ខ្លួន និងឃុំខ្លួនអ្នកដែលហ៊ានក្រោកឈរតស៊ូមតិ ដើម្បីសិទ្ធិរបស់អ្នកទាំងនោះ ។

### វិសោធនកម្មរដ្ឋធម្មនុញ្ញ

*កាលពីខែកុម្ភៈ ឆ្នាំ២០១៨ រដ្ឋសភាជាតិបានអនុម័តលើសេចក្តីព្រាងវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេស ដោយរឹតត្បិតលទ្ធភាពរបស់ពលរដ្ឋ ក្នុងការចូលរួមក្នុងកិច្ចការនយោបាយ និងលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសជាតិ ។ វិសោធនកម្មទាំងនេះ ហាមឃាត់ប្រជាពលរដ្ឋពី "សកម្មភាពទាំងឡាយណា" ដែល "ប៉ះពាល់ដល់ប្រយោជន៍ប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជា" ទោះដោយប្រយោលក្តី ដោយផ្ទាល់ក្តី ក៏ដូចជារឹតត្បិតសិទ្ធិរបស់ពលរដ្ឋក្នុងការចូលរួមក្នុងការបោះឆ្នោត និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម ដោយតម្រូវឱ្យទាំងគណបក្សនយោបាយ និងពលរដ្ឋសាមញ្ញ "តម្កល់ប្រយោជន៍ជាតិជាធំ" ។ វិសោធនកម្មទាំងនេះ ចែងនូវវិធានការរឹតត្បិតយ៉ាងស្រពិចស្រពិល និងដោយមិនត្រឹមត្រូវ លើសេរីភាពនៃការបញ្ចេញមតិ ការបង្កើតសមាគម និងការប្រមូលផ្តុំនានា ។*

### ច្បាប់ហាមឃាត់ការប្រមាថអង្គព្រះមហាក្សត្រ

*ដូចគ្នាដែរ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨ រដ្ឋសភាជាតិ ក៏បានអនុម័តនូវសេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌកម្ពុជា ដោយដាក់ទោសពីបទល្មើសព្រហ្មទណ្ឌលើការប្រមាថណាមួយដែលធ្វើឡើងមកលើអង្គព្រះមហាក្សត្រ ។ មាត្រាថ្មីនេះ (ដែលអាចដាក់ទោសពន្ធនាគារពីមួយឆ្នាំ ដល់ប្រាំឆ្នាំ រួមទាំងប្រាក់ពិន័យទៅលើការបញ្ចេញមតិណាមួយពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានលក្ខណៈប្រមាថដល់ទឹកដីនៃប្រទេសជាតិ) ត្រូវបានគេប្រើប្រាស់ ដើម្បីចោទប្រកាន់ និងចាប់ខ្លួនពលរដ្ឋចំនួនបីនាក់ នៅពេលដែលអ្នកទាំងបីបានចែករំលែកលើបណ្តាញសង្គមនូវអត្ថបទដែលមានលក្ខណៈប្រមាថព្រះមហាក្សត្រ ពីរបីខែក្រោយវិសោធនកម្មនៃច្បាប់នោះចូលជាធរមាន ។*

### ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

*អំឡុងពេលរីករាលដាលនៃការឆ្លងមេរោគ កូវីដ ១៩ កាលពីខែមេសា រដ្ឋសភាបានអនុម័តច្បាប់មួយដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលប្រកាសដាក់ប្រទេសក្នុងស្ថានភាពអាសន្ន ដើម្បីឆ្លើយតបនឹង "គ្រោះថ្នាក់" ដែលមិនច្បាស់លាស់ដែលអាចកើតមានឡើងក្នុងប្រទេស ។ ពាក្យពេចន៍ដែលត្រូវបានប្រើប្រាស់មួយចំនួនក្នុងច្បាប់នេះ នៅមានភាពស្រពិចស្រពិល ដែលធ្វើឱ្យអាជ្ញាធររដ្ឋមានអំណាចលើសលុប ក្នុងការរឹតត្បិតសិទ្ធិសេរីភាពជាមូលដ្ឋាននានា រួមមានទាំងសេរីភាពក្នុងការជួបជុំ បញ្ចេញមតិ ធ្វើដំណើរ ធ្វើការងារ និងកាន់កាប់ទ្រព្យសម្បត្តិ ។*

*ច្បាប់នេះ មិនត្រឹមតែកំណត់នូវទោសព្រហ្មទណ្ឌយ៉ាងធ្ងន់ធ្ងរចំពោះបទល្មើសមួយចំនួន ដែលត្រូវបានចែងដោយមិនច្បាស់លាស់ ដូចជាបទល្មើស "មិនគោរព" វិធានការរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ហើយច្បាប់នេះក៏ផ្តល់អំណាចដល់អាជ្ញាធររដ្ឋដាក់នីតិបុគ្គលស្របច្បាប់មួយចំនួន ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌលើបទល្មើសដែលចែងមិនច្បាស់លាស់ផងដែរ ។ នៅក្រោមមាត្រាទាំងនេះ អង្គការ សមាគម សហជីព ឬក្រុមពលរដ្ឋណាមួយអាចត្រូវបានរំលាយចោល ប្រសិនបើសមាជិករបស់ស្ថាប័ន ឬក្រុមនោះ មានពិរុទ្ធភាពដោយសាររំលោភបទបញ្ជាដែលចែងមិនច្បាស់នានា នៅក្នុងស្ថានភាពនៃការដាក់ប្រទេសស្ថិតក្នុងគ្រាអាសន្ន ។*

## សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ

សេចក្តីព្រាងច្បាប់នេះ ត្រូវបានលេចចេញជាសាធារណៈកាលពីខែមិថុនា ហើយប្រសិនបើត្រូវបានរដ្ឋសភាអនុម័តដោយឥតកែប្រែអ្វី នឹងរឹតត្បិតយ៉ាងខ្លាំងស្ទើរគ្រប់ផ្នែកនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ចំណុចសំខាន់ៗមួយចំនួនក្នុងសេចក្តីព្រាងច្បាប់នេះ រួមមានការដាក់ទោសព្រហ្មទណ្ឌទៅលើស្ត្រីដែលស្លៀកពាក់ខ្លីខើចលើខើចក្រោម ឬ ស្លៀកពាក់ស្តើងមើលឃើញកេរភេទ ហាមឃាត់មនុស្សដែលមានជំងឺផ្នែកសតិស្មារតី (មាត្រានេះ ចែងមិនច្បាស់លាស់ថាលក្ខខណ្ឌបែបណាខ្លះដែលធ្វើឱ្យមនុស្សលែងដឹង "ខុស" ដឹង "ត្រូវ") មិនឱ្យចេញទៅទីសាធារណៈដោយមិនមានអ្នកមើលថែរក្សាទៅជាមួយ និងហាមឃាត់សកម្មភាពប្រចាំថ្ងៃជាមូលដ្ឋានមួយចំនួនទៀត ដូចជាការដុតសម្រាម ព្យួរឬហាលខោអាវនៅទីសាធារណៈ លក់ម្ហូបអាហារឬផលិតផលនានានៅលើដងផ្លូវ ការសុំទាននៅទីសាធារណៈគ្រប់រូបភាព ។

ការចេញនូវសេចក្តីព្រាងច្បាប់នេះ ក៏បង្កើតឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងផងដែរទៅលើសេរីភាពនៃការជួបជុំនិងការប្រមូលផ្តុំ ។ គ្រប់ព្រឹត្តិការណ៍សាធារណៈទាំងអស់ អាចត្រូវបានអាជ្ញាធរបញ្ឈប់ ប្រសិនបើអាជ្ញាធរកំណត់ថា ការរៀបចំព្រឹត្តិការណ៍នោះបានរំខានដល់ស្ថេរភាពសង្គម និងប្រពៃណីសេចក្តីថ្លៃថ្នូររបស់ជាតិ ជាឃ្លាមួយដែលមានលក្ខណៈមិនច្បាស់លាស់នៅក្នុងសេចក្តីព្រាងច្បាប់ ។ ការ "បង្កការប្រទូសរ៉ាយជាមួយកងកម្លាំងសមត្ថកិច្ច" ក៏ជាមូលហេតុមួយដែលអាចបញ្ឈប់ព្រឹត្តិការណ៍ណាមួយបានផងដែរ ។ សេចក្តីព្រាងច្បាប់នេះ ក៏បានកម្រិតចំនួនមនុស្សដែលចូលរួមព្រឹត្តិការណ៍សាធារណៈទាំងនោះ ដោយមិនត្រឹមត្រូវផងដែរ ។ ប្រសិនបើច្បាប់នេះត្រូវបានរដ្ឋសភាអនុម័ត វានឹងរឹតត្បិតសិទ្ធិសេរីភាពជាមូលដ្ឋានយ៉ាងខ្លាំងនៅក្នុងសកម្មភាពជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដែលរួមមានទាំងសិទ្ធិក្នុងការជួបជុំ ឬប្រមូលផ្តុំ ដោយច្បាប់នេះផ្តល់អំណាចដល់អាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តការរឹតត្បិតនេះតាមការយល់ឃើញរបស់មន្ត្រីទាំងនោះ ។

## សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន

សេចក្តីព្រាងច្បាប់នេះ ដែលត្រូវបានលេចចេញជាសាធារណៈ កាលពីខែសីហា ឆ្នាំ២០២០ បានបង្ហាញយ៉ាងច្បាស់ពីបំណងរបស់គណបក្សកាន់អំណាច ក្នុងការគ្រប់គ្រងត្រួតពិនិត្យលើសកម្មភាពនៅលើបណ្តាញអ៊ិនធើណេតរបស់ប្រជាពលរដ្ឋ ។ ប្រសិនបើមិនទាន់មានការកែប្រែថ្មីណាមួយក្នុងសេចក្តីព្រាងច្បាប់នោះទេ សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់អំណាចយ៉ាងច្រើនលើសលុបដល់រាជរដ្ឋាភិបាល ក្នុងការឃ្លាំមើល និងដាក់ទោសលើការបញ្ចេញមតិណាមួយនៅលើបណ្តាញអ៊ិនធើណេត ។ លើសពីនេះ យោងតាមសេចក្តីព្រាងច្បាប់នេះ អាជ្ញាធររដ្ឋមានសិទ្ធិកត់ត្រាទុកទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់អ៊ិនធើណេត ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកប្រើប្រាស់ ដោយសំអាងលើមូលហេតុដើម្បីរក្សា "សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម" ។ គួរឱ្យព្រួយបារម្ភជាងនេះទៅទៀត សេចក្តីព្រាងច្បាប់នេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនូវ "ការផ្សព្វផ្សាយព័ត៌មានមិនពិត និងក្លែងក្លាយ" នៅលើបណ្តាញអ៊ិនធើណេត នៅក្នុងមាត្រាមួយដែលសំដៅលើសេចក្តីថ្លៃថ្នូរណាមួយ ដែល "ធ្វើឱ្យបាត់បង់ទំនុកចិត្តសាធារណៈលើការបំពេញភារកិច្ច ឬមុខងារ ឬការអនុវត្តអំណាច របស់រដ្ឋាភិបាល ឬស្ថាប័នរដ្ឋ" ។ ដោយសារតាំងពីដើមរៀងមក អាជ្ញាធររដ្ឋតែងតែចោទប្រកាន់អ្នកដែលបញ្ចេញមតិរិះគន់សកម្មភាពរបស់អាជ្ញាធររដ្ឋ ថាជារឿងនយោបាយ មាត្រាខាងលើនេះអាចនឹងជាការរឹតត្បិតបន្ថែមទៀត លើអ្នកប្រើប្រាស់បណ្តាញអ៊ិនធើណេត ក្នុងការបញ្ចេញមតិរបស់អ្នកទាំងនោះអំពីបញ្ហាសង្គម នយោបាយ ឬសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

## អនុក្រឹត្យស្តីពីច្រកទ្វារអ៊ិនធើណេតជាតិ

*កាលពីថ្ងៃទី៨ ខែកក្កដា រាជរដ្ឋាភិបាលបានព្រាងនូវអនុក្រឹត្យមួយស្ដីពីការបង្កើតប្រតិបត្តិករច្រកទ្វារអ៊ិនធើណេតជាតិមួយ ដែលនឹងមានតួនាទីក្នុងការធ្វើការងារជាមួយអាជ្ញាធររដ្ឋ ក្នុងការបិទ ឬកាត់ផ្ដាច់រាល់បណ្ដាញទាំងឡាយណាដែលប៉ះពាល់ដល់ "សណ្ដាប់ធ្នាប់សង្គម កិត្តិយស សេចក្ដីថ្លៃថ្នូរ វប្បធម៌ប្រពៃណី និងទំនៀមទំលាប់របស់ជាតិ" និងធ្វើការសហការ "ដើម្បីធានានូវសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម" ។ អនុក្រឹត្យនេះ អាចនឹងត្រូវបានប្រើប្រាស់ ដើម្បីបិទគេហទំព័ររបស់ក្រុមសង្គមស៊ីវិលមួយចំនួន និងរារាំងប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់អ៊ិនធើណេត ដោយមិនឱ្យចូលទៅមើលអត្ថបទក្នុងគេហទំព័រណាមួយដែលរិះគន់រាជរដ្ឋាភិបាល ។ អនុក្រឹត្យនេះ ធ្វើឱ្យយើងនឹកឃើញពីបទបញ្ជារបស់រាជរដ្ឋាភិបាលកាលពីមុនការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៨ ដែលបានបញ្ជាឱ្យក្រុមហ៊ុនផ្ដល់សេវាអ៊ិនធើណេតបិទគេហទំព័រព័ត៌មាន និងគេហទំព័រដែលស្និតនឹងគណបក្សជំទាស់មួយចំនួន ។ អនុក្រឹត្យនេះក៏តម្រូវឱ្យអ្នកផ្ដល់សេវាអ៊ិនធើណេត រក្សាទុកទិន្នន័យចរាចរលើបណ្ដាញអ៊ិនធើណេតពេញមួយឆ្នាំ ដែលនេះជាការទុកឱ្យមានការរំលោភលើសិទ្ធិឯកជនភាពរបស់អ្នកប្រើប្រាស់បណ្ដាញអ៊ិនធើណេត នៅពេលក្រោយទៀត ។*

## សេចក្ដីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ

*ការប្រគល់ដីសាធារណៈឱ្យទៅបុគ្គលឯកជនគ្រប់គ្រង គឺជាមូលហេតុចម្បងដែលបណ្ដាលឱ្យមានជម្លោះដីធ្លីជាច្រើនបានកើតមានឡើង ដែលជម្លោះទាំងនោះធ្វើឱ្យពលរដ្ឋសហគមន៍ជាច្រើននៅទូទាំងប្រទេសបាត់បង់ផ្ទះសម្បែងរបស់អ្នកទាំងនោះ ។ ការប្រគល់ដីបែបនេះ អាចនឹងកើតឡើងញឹកញាប់ជាងមុន ក្រោយពេលដែលសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ បានចូលជាធរមាន ដែលសេចក្ដីព្រាងច្បាប់នេះ នឹងផ្ដល់ក្របខណ្ឌច្បាប់ក្នុងការធ្វើអនុប្បយោគដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ ហើយនិងការប្រគល់ដីសាធារណៈរបស់រដ្ឋទាំងនោះ ទៅឱ្យបុគ្គលឯកជនសម្រាប់ "ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គម" ។ ការលេចចេញនូវរូបរាងនៃការគ្រប់គ្រងដីធ្លីបែបនេះអាចនឹងរួមចំណែកបង្កឱ្យជម្លោះដីធ្លីជាមួយពលរដ្ឋសហគមន៍មូលដ្ឋាន ។ ការព្រួយបារម្ភមួយទៀតគឺសេចក្ដីព្រាងច្បាប់នេះ អាចនឹងបិទរាល់លទ្ធភាពនៃការអះអាងពីម្ចាស់កម្មសិទ្ធិ តែអាចនឹងអនុញ្ញាតឱ្យមានការបណ្ដេញចេញភ្លាមៗទៅលើពលរដ្ឋដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ ដោយមិនមានសំណងណាមួយនោះទេ ។ សេចក្ដីព្រាងច្បាប់នេះ បច្ចុប្បន្នកំពុងត្រូវបានពិនិត្យមើលដោយព្រឹទ្ធសភាដែលមានសមាសភាពសុទ្ធតែពីគណបក្សកាន់អំណាច ។*

ជារួម ច្បាប់ទាំងនេះនឹងបង្កើនអំណាចឥតដែនកំណត់ដល់អាជ្ញាធររដ្ឋ ដើម្បីគាបសង្កត់ និងរឹតត្បិតសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋ ជាពិសេសលើអ្នកដែលធ្វើការងារការពារសិទ្ធិមនុស្សទាំងឡាយ ។ ប្រសិនបើសេចក្ដីព្រាងច្បាប់ទាំងនោះ មិនមានការកែប្រែគួរឱ្យកត់សំគាល់ណាមួយនោះទេ ឬច្បាប់ទាំងនោះ មិនមានការធ្វើវិសោធនកម្ម គួរឱ្យកត់សំគាល់ណាមួយនោះទេ ហើយមិនមានយុទ្ធនាការរួមណាមួយជំទាស់នឹងការអនុម័តលើសេចក្ដីព្រាងច្បាប់ ឬអនុវត្តច្បាប់ទាំងនោះ លំហសិទ្ធិនិងសេរីភាពរបស់ក្រុមសង្គមស៊ីវិល និងពលរដ្ឋសហគមន៍មូលដ្ឋាន ក្នុងការតស៊ូមតិដើម្បីសមាជិកពលរដ្ឋសហគមន៍ និងប្រជាពលរដ្ឋទូទៅ នឹងត្រូវបានរឹតត្បិតយ៉ាងខ្លាំង ។



កម្មករជាច្រើននាក់ជួបជុំគ្នានៅទីលានប្រជាធិបតេយ្យភ្នំពេញ ដើម្បីចូលរួមអបអរសាទរទិវាពលកម្មអន្តរជាតិ ឆ្នាំ២០១៩

# ការដើរឆ្ពោះទៅមុខ

ឆ្នាំ ២០២០ គឺជាឆ្នាំដំបូងចាប់តាំងពីបញ្ចប់សង្គ្រាមស៊ីវិលនៅក្នុងប្រទេស ដែលទិវាសិទ្ធិមនុស្សអន្តរជាតិ នឹងមិនត្រូវបានគេប្រារព្ធឡើង ។ កាលពីឆ្នាំមុន គណបក្សកាន់អំណាច បានសម្រេចដកទិវាសិទ្ធិមនុស្សអន្តរជាតិ ថ្ងៃទី១០ ខែធ្នូ ចេញពីបញ្ជីថ្ងៃឈប់សម្រាកប្រចាំឆ្នាំរបស់ជាតិ ។ ការគ្មានឆន្ទៈនឹងបន្តប្រារព្ធទិវាអន្តរជាតិនេះ គឺជាសារមួយយ៉ាងធ្ងន់ ដល់អ្នកការពារសិទ្ធិមនុស្សទាំងឡាយនៅក្នុងប្រទេស ។

ដោយសមាសភាពទាំងអស់ក្នុងរដ្ឋសភា មកពីគណបក្សកាន់អំណាច មន្ត្រីជាន់ខ្ពស់នៃស្ថាប័នតុលាការ ក៏សុទ្ធតែជាសមាជិកគណបក្សកាន់អំណាច ហើយស្ថាប័នសារព័ត៌មានច្រើនលើសលុបជាស្ថាប័នស្និទ្ធនឹងគណបក្សកាន់អំណាច ដូចនេះគណបក្សកាន់អំណាច ក្រោយពីរំលាយគណបក្សជំទាស់រួច ត្រូវបានសាធារណជនយល់ថា អាចនឹងចំណាយពេលទៅមុខ ដើម្បីពង្រឹងអំណាចយ៉ាងរឹងមាំ និងគ្រប់គ្រងយ៉ាងពេញដៃ ទៅលើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ប៉ុន្តែទោះជារងការចាប់ខ្លួន និងការគំរាមកំហែងឥតឈប់ឈរមកលើការប្រមូលផ្តុំ និងក្រុមរបស់ប្រជាសហគមន៍មូលដ្ឋាន កសិករ កម្មករ សកម្មជន យ៉ាងណាក៏ដោយ ក៏អ្នកទាំងនោះនៅតែបន្តបន្លឺសំឡេង តាមរយៈការតវ៉ានានាជំទាស់នឹងការធ្លាក់ចុះជារៀងរាល់ថ្ងៃ នូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់អ្នកទាំងនោះ និងរបស់ប្រជាពលរដ្ឋក្នុងប្រទេស ។

ការងារជាអ្នកការពារសិទ្ធិមនុស្ស ក្នុងការហ៊ានក្រោកឈរបញ្ចេញមតិ ដើម្បីទាមទារឱ្យមានការគោរពសិទ្ធិសេរីភាពជាមូលដ្ឋាន គឺជាការងារដែលមានការលះបង់ខ្ពស់សម្រាប់ប្រជាពលរដ្ឋដែលចេញតវ៉ា អ្នកកាសែត អ្នកតំណាងសហគមន៍ជាច្រើន ដែលពេលខ្លះអ្នកទាំងនោះត្រូវលះបង់ពេលវេលាជាច្រើនឆ្នាំរស់នៅយ៉ាងលំបាកក្នុងពន្ធនាគារ ជាជាងការចុះចាញ់និងទទួលយកនូវភាពអយុត្តិធម៌ក្នុងសង្គម ។ ប្រសិនបើសេចក្តីព្រាងច្បាប់នានា ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ ត្រូវបានអនុម័ត លទ្ធភាពរបស់អ្នកការពារសិទ្ធិមនុស្សក្នុងការតស៊ូមតិ ដើម្បីក្រុមគ្រួសាររបស់អ្នកទាំងនោះ និងដើម្បីសហគមន៍មូលដ្ឋាន នឹងត្រូវបាត់បង់ ។ ប៉ុន្តែទឹកចិត្តក្លាហាន ដែលជំរុញឱ្យអ្នកទាំងនោះក្រោកឈរចេញតវ៉ាអស់រយៈពេលជាច្រើនទសវត្សរ៍ និងភាពសកម្មនិយមរបស់អ្នកទាំងនោះ នៅតែមិនសាបសូន្យ ជាមួយនឹងការស្វែងរកទម្រង់ថ្មីជាច្រើនផ្សេងទៀតតាមរយៈពាក្យសម្តី និងកាយវិការរបស់មនុស្សជំនាន់ក្រោយ ដែលបន្តទឹកចិត្តក្លាហាន ហ៊ានប្រឈមមុខ ដើម្បីសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ។

# អនុសាសន៍

**ជូនទៅកាន់រាជរដ្ឋាភិបាល និងអាជ្ញាធររដ្ឋ ៖**

- សូមដោះលែងអ្នកការពារសិទ្ធិមនុស្សដែលកំពុងជាប់ពន្ធនាគារដោយមិនត្រឹមត្រូវ

- សូមធ្វើការស៊ើបអង្កេតឱ្យបានឆាប់រហ័ស ម៉ត់ចត់ និងឯករាជ្យ ទៅលើការគំរាមកំហែង និងការរំលោភបំពាននានាមកលើអ្នកការពារសិទ្ធិមនុស្ស និងសូមផ្តន្ទាទោសជនល្មើសឱ្យស័ក្តសមទៅតាមទោសក្នុងច្បាប់ជាធរមាន

- សូមបញ្ឈប់ការបង្ក្រាបដោយមិនត្រឹមត្រូវ មកលើពលរដ្ឋដែលចេញតវ៉ាដោយអហិង្សា ដោយគ្រាន់តែអ្នកទាំងនោះអនុវត្តសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំ និងបញ្ចេញមតិ ។ សូមបញ្ឈប់ការប្រើប្រាស់កងកម្លាំង ដែលរួមមានកងសន្តិសុខខណ្ឌ បង្ក្រាបមកលើការតវ៉ា និងបាតុកម្មដោយអហិង្សានានា ។

- សូមធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីធានាថាស្របតាមរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលយោងតាមអនុសញ្ញាស្តីពីសិទ្ធិមនុស្សនានា ដែលកម្ពុជាបានផ្តល់សច្ចាប័ន ។ ជាពិសេស សូមធ្វើវិសោធនកម្មលើមាត្រាដែលចែងមានលក្ខណៈស្រពិចស្រពិល ដូចជាមាត្រានៃបទល្មើសញុះញង់ និងមាត្រាផ្សេងទៀតដែលប៉ះពាល់ដល់សិទ្ធិក្នុងការបញ្ចេញមតិ ដូចជាមាត្រានៃបទល្មើសបរិហារកេរ្តិ៍ និងប្រមាថ ដើម្បីធានាថាមាត្រាទាំងនោះមិនរឹតត្បិតដល់សេរីភាពក្នុងការបញ្ចេញមតិ និងមិនអនុញ្ញាតឱ្យមានការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្សដោយមិនត្រឹមត្រូវនោះទេ ។

- សូមលុបចោលច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សូមធ្វើវិសោធនកម្មមាត្រាដែលមិនត្រឹមត្រូវមួយចំនួន ឬលុបចោលទាំងស្រុងនូវច្បាប់ស្តីពីសហជីពពាណិជ្ជកម្ម និងច្បាប់ពាក់ព័ន្ធនឹងការរឹតត្បិតសិទ្ធិកម្មករដទៃទៀត ។

- សូមធ្វើវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ន ដើម្បីធ្វើឱ្យប្រទេសជាតិគោរពនូវគោលការណ៍សិទ្ធិមនុស្ស និងធានាថាច្បាប់ដែលនឹងត្រូវបានអនុម័តក្រោយៗទៀត គោរពនូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលជាកាតព្វកិច្ចរបស់កម្ពុជាតាមច្បាប់អន្តរជាតិ ។

**ជូនទៅកាន់សហគមន៍អន្តរជាតិ ៖**

- សូមរដ្ឋ និងស្ថាប័នអន្តរជាតិនានា ជួយបន្តអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា សូមឱ្យបញ្ឈប់ការរំលោភបំពានមកលើក្រុមសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា តាមរយៈកិច្ចសន្ទនាជាមួយអាជ្ញាធររដ្ឋកម្ពុជា និងការអំពាវនាវជាសាធារណៈ ។

- រដ្ឋជាច្រើនដែលមានយន្តការដាក់ទណ្ឌកម្មលើជនដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ គួរពិចារណាអនុវត្តនូវយន្តការទាំងនោះ ដើម្បីស៊ើបអង្កេតបុគ្គល និងក្រុមហ៊ុនដែលរួមគំនិតក្នុងការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ។

- សូមអ្នកតំណាងរបស់រដ្ឋ និងស្ថាប័នពហុភាគីនានា ជួយស្នើសុំចូលសួរសុខទុក្ខអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ និងជួយឃ្លាំមើលសវនាការសំខាន់ៗនិងព្រឹត្តិការណ៍សំខាន់ៗពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយនានា ។

- សូមអ្នកតំណាងរបស់រដ្ឋ និងស្ថាប័នពហុភាគីនានា គួរបង្ហាញពីសាមគ្គីភាព និងប្រតិកម្មឱ្យបានធ្ងន់ជាសាធារណៈ ចំពោះសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជាថ្មីៗនេះ ដែលបានបំភិតបំភ័យ និងចាប់ខ្លួនសកម្មជនជាច្រើន ហើយសូមឱ្យអ្នកទាំងនោះជួយអំពាវនាវដល់អាជ្ញាធរកម្ពុជា ឱ្យទំលាក់ចោលរាល់បទចោទប្រកាន់ទាំងអស់មកលើអ្នកតវ៉ាដោយអហិង្សាដែលកំពុងជាប់ពន្ធនាគារ ដោយគ្រាន់តែអ្នកទាំងនោះអនុវត្តនូវសិទ្ធិជាមូលដ្ឋានក្នុងការបញ្ចេញមតិ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញប៉ុណ្ណោះ ។

# ឧបសម្ព័ន្ធ៖ ការរំលោភបំពានទៅលើអ្នកការពារសិទ្ធិមនុស្សថ្មីៗនេះ

ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០១៨

## សកម្មជនការពារព្រៃឈើប្រឈមនឹងការគំរាមកំហែងតាមទូរស័ព្ទដៃ

សមាជិកបណ្ដាញសហគមន៍ព្រៃឡង់ម្នាក់នៅខេត្តព្រះវិហារ បានទទួលការគំរាមកំហែងតាមរយៈការហៅទូរស័ព្ទប្រាប់ឱ្យប្រយ័ត្នខ្លួន បន្ទាប់ពីលោក និងសមាជិកសហគមន៍ ៤ នាក់ផ្សេងទៀតរួមទាំងមន្ត្រីបរិស្ថានស្រុកចំនួន ២ នាក់បានដកហូតបានសម្ភារៈដឹកជញ្ជូនឈើខុសច្បាប់រួមមាន ត្រាក់ទ័រ រណារច្រវ៉ាក់ និងឈើប្រណិត ពីអ្នកភូមិចំនួន ៥ នាក់ ដែលត្រូវបានគេជឿជាក់ថា បានឃុបឃិតជាមួយអាជ្ញាធរមូលដ្ឋាន ខណៈពេលដែលលោក និងសហគមន៍ទាំង ៤ នាក់ កំពុងល្បាតព្រៃសហគមន៍ ។

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨

## ការគំរាមកំហែងដោយភ្ជង់កាំភ្លើងលើសកម្មជនការពារព្រៃឈើ

លោក លឿត ឡោះ ដែលជាអនុប្រធានសហគមន៍ព្រៃឈើព្រះនេត្រព្រះ ត្រូវបានគំរាមដោយការភ្ជង់កាំភ្លើងខ្លីពីសំណាក់ក្រុមទាហាន ៧នាក់នៅស្រុកសំរោង ខេត្តឧត្តរមានជ័យ ខណៈដែល លោក ឡោះ និងមនុស្ស ៤ នាក់ផ្សេងទៀតកំពុងល្បាតព្រៃសហគមន៍ ហើយព្យាយាមរារាំងជនល្មើសដែលកំពុងដឹកជញ្ជូនឈើប្រណិតចេញពីតំបន់ការពារ ។

ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨

## តំណាងសហគមន៍ត្រូវបានហៅទៅសាកសួរ

តំណាងប្រជាពលរដ្ឋចំនួន ៤ នាក់ មកពីសហគមន៍មួយនៅខេត្តបន្ទាយមានជ័យ ត្រូវបានកោះហៅទៅសាកសួរដោយមេនគរបាលឃុំ បន្ទាប់ពីបានរៀបចំការប្រជុំគ្នា ដើម្បីពិភាក្សាអំពីដំណោះស្រាយទំនាស់ដីធ្លី ។ អ្នកតំណាងទាំង ៤ នាក់ ត្រូវបានបង្ខំឱ្យផ្ដិតមេដៃលើកិច្ចព្រមព្រៀងមួយដោយសន្យាថា នឹងមិនប្រមូលផ្ដុំគ្នាម្ដងទៀតដោយគ្មានការអនុញ្ញាតច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន ពុំនោះទេនឹងអាចរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៨

## តំណាងសហគមន៍ត្រូវបានចាប់ខ្លួន

តំណាងសហគមន៍កោះកុងលោក ហេង សុខ ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន ដោយលោក ព្រុំ វណ្ណី អធិការរងនគរបាលស្រុក បន្ទាប់ពីមេបញ្ជាការម្នាក់នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុងបានចោទប្រកាន់លោកពីបទប្រព្រឹត្តិអំពើហិង្សា ។ ដីស្រែជាង ១០០ ហិកតា ដែលកាន់កាប់ដោយប្រជាពលរដ្ឋ ៥០ គ្រួសារចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ ត្រូវបានរឹបអូសយកនៅក្នុងឆ្នាំ ២០០៥ ដើម្បីធ្វើការបើកផ្លូវសម្រាប់តំបន់សេដ្ឋកិច្ចពិសេស ដែលគ្រប់គ្រងដោយលោកឧកញ៉ា លី យ៉ុងផាត់ ដែលជាសមាជិកព្រឹទ្ធសភាមកពីគណបក្សកាន់អំណាច ។

*ករណីទាំងអស់នេះត្រូវបានដកស្រង់ចេញពីរបាយការណ៍ឃ្លាំមើលលីកាដូ ដែលមិនបានផ្សព្វផ្សាយ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។ អ្នកនយោបាយ និងសកម្មជននយោបាយ ក៏អាចដើរតួជាអ្នកការពារសិទ្ធិមនុស្សផងដែរ ។ ទោះយ៉ាងណា រដ្ឋាភិបាលកម្ពុជាមានប្រវត្តិចោទទៅលើអ្នករិះគន់ថា ជាគណបក្សប្រឆាំង ដើម្បីលុបបំបាត់នូវការរិះគន់ និងការតវ៉ាដោយស្របច្បាប់ ។ ក្នុងបរិបទនេះ លីកាដូ មិនបានរាប់បញ្ចូលនូវការរំលោភបំពាន និងការគំរាមកំហែងដល់អ្នកនយោបាយ ឬសកម្មជននយោបាយនៅក្នុងឧបសម្ព័ន្ធនេះទេ ។

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨

### មេដឹកនាំសង្គមស៊ីវិលរងការបង្ខូចឈ្មោះ ថាពាក់ព័ន្ធនឹងបដិវត្តពណ៌

អង្គភាពព័ត៌មាននិងប្រតិកម្មរហ័សរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញផ្សាយវីដេអូឃោសនាមួយស្តីពីកម្ពុជា អំពីការសមគំនិតបដិវត្តពណ៌ ដោយចោទប្រកាន់លោក វ៉ន ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងលោក ថេង សាវឿន ប្រធានសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងលោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ថាជាប់ពាក់នឹងគម្រោងបដិវត្តពណ៌ ។ ប្រភពសារព័ត៌មានរបស់រដ្ឋាភិបាល Fresh News ក៏មានមតិយោបល់មួយ ដែលនិយាយឡើងវិញនូវការចោទប្រកាន់ដោយគ្មានមូលដ្ឋាននេះ ។

ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨

### និពន្ធនាយកត្រូវបានបណ្តេញចេញពីស្ថាប័នកាសែត

លោក កែ គឹមសុង និពន្ធនាយកកាសែតភ្នំពេញប៉ុស្តិ៍ត្រូវបានបណ្តេញចេញពីការងារដោយម្ចាស់កាសែតថ្មី ដែលជាពាណិជ្ជករម៉ាឡេស៊ីឈ្មោះ ស៊ីវ៉ាគូម៉ា អេស ហ្គាណាផាតស៊ី បន្ទាប់ពីកាសែតនេះបានចុះផ្សាយអត្ថបទទាក់ទងនឹងទំនាក់ទំនងជាសាធារណៈរវាងក្រុមហ៊ុនរបស់លោក ហ្គាណាផាតស៊ី ជាមួយនិងរាជរដ្ឋាភិបាល ។ ការីនិពន្ធ ៣ នាក់ និងអ្នកយកព័ត៌មានជាង ១២ នាក់ ក៏បានលាឈប់បន្ទាប់ពីអ្នកគ្រប់គ្រងថ្មីបានស្នើសុំឱ្យបុគ្គលិកដកអត្ថបទនោះចេញពីគេហទំព័ររបស់កាសែត ។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨

### តំណាងសហគមន៍ត្រូវបានគំរាមកំហែង មិនឱ្យធ្វើដំណើរទៅរាជធានីភ្នំពេញ

តំណាងសហគមន៍ដីធ្លីនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ ត្រូវបានគំរាមកំហែងដោយមេភូមិ និងមេប៉ុស្តិ៍ បន្ទាប់ពីពួកគាត់គ្រោងធ្វើដំណើរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅរាជធានីភ្នំពេញ ដើម្បីស្វែងរកដំណោះស្រាយចំពោះរឿងជំលោះដីធ្លី ដែលមានជាយូរមកហើយជាមួយក្រុមហ៊ុន ម៉ែនសារុន អាហារ័ណ នីហរ័ណ ។ មុនមួយថ្ងៃ អ្នកតំណាងសហគមន៍មកពីឃុំក្បែរនោះ ត្រូវបានបង្ខំឱ្យផ្តិតមេដៃលើកិច្ចសន្យាថា មិនធ្វើដំណើរទៅរាជធានីភ្នំពេញ បន្ទាប់ពីពួកគាត់ប្រមូលគ្នាបានជាង ២០០ គ្រួសារ និងបានរៀបចំធ្វើដំណើរទៅរាជធានីភ្នំពេញ ដើម្បីស្វែងរកដំណោះស្រាយ។ អ្នកតំណាងសហគមន៍ទាំង ៣ នាក់ត្រូវបានអាជ្ញាធរទាំងនោះគម្រាមថា នឹងចាត់វិធានការតាមផ្លូវច្បាប់ ។

ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨

### អ្នកកាសែតត្រូវបានគម្រាមកំហែងដោយពាណិជ្ជករមានទ្រព្យ

លោក យួន ឈីវ អ្នកកាសែតនៅកាសែត Today ទទួលការគំរាមសម្លាប់ពីបុរសអ្នកមានលុយ ពីរនាក់នៅក្នុងស្រុកបុទុមសាគរ ខេត្តកោះកុង ។ មនុស្សម្នាក់ក្នុងចំនោមអ្នកពីរនាក់ បានគំរាមសម្លាប់អ្នកកាសែតដោយដៃរបស់លោកផ្ទាល់ រីឯ លោក ជា សុថាវរិទ្ធ ដែលធ្លាប់វាយដំទៅលើលោក ឈីវ បានបង្ហោះមតិនៅលើទំព័រហ្វេសប៊ុករបស់លោកឈីវ ដោយបង្ហាញរូបកាំភ្លើង និងគំរាមដល់អាយុជីវិតរបស់លោក ។ លោក ឈីវ ដែលតែងតែផ្សាយរឿងរ៉ាវទាក់ទងនិងជម្លោះដីធ្លី អំពើពុករលួយ និងនិទណ្ឌភាពរបស់បុរសមានអំណាចនោះ ។ ហើយលោកក៏បានធ្វើការរិះគន់ជាសាធារណៈទៅលើបុរសទាំងពីរនោះ ដោយចោទប្រកាន់ថាពួកគេបានសង់ផ្ទះមួយនៅលើស្រះទឹក ដែលជាហេតុធ្វើឱ្យមានទឹកជន់លិចនៅក្នុងភូមិ ។

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨

### អ្នកការពារសិទ្ធិមនុស្សត្រូវបានគំរាមកំហែងពីខុទ្ទកាល័យនាយករដ្ឋមន្ត្រី

លោក យី សុខសាន បុគ្គលិកជាន់ខ្ពស់សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ត្រូវបានចោទប្រកាន់ដោយលោក គង់ ចំរើន លេខាធិការខុទ្ទកាល័យនាយករដ្ឋមន្ត្រី ពីបទញុះញង់ក្រុមគ្រួសារដែលរងផលប៉ះពាល់ពីការរំលោភយកដីធ្លី ដើម្បីធ្វើដំណើរមកតវ៉ានៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញ ។ កន្លងមកលោក សុខសាន បានធ្វើការជាមួយក្រុមគ្រួសារដែលមានជម្លោះដោយសារការសាងសង់ខ្សែបណ្តាញអគ្គីសនីជាមួយក្រុមហ៊ុន សាជីវកម្មគ្រឿងចក្រធន់ធ្ងន់ចិន ។

ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨

### តំណាងសមាគមកម្មករក្រៅប្រព័ន្ធត្រូវបានគំរាមកំហែង

បុរសមិនស្គាល់អត្តសញ្ញាណចំនួន ៤ នាក់បានចូលទៅក្នុងផ្ទះរបស់សមាជិកសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធស្ថិតនៅ ខេត្តបន្ទាយមានជ័យ ។ គាត់មិននៅផ្ទះទេ ប៉ុន្តែកូនប្រុសគាត់បានផ្ទះ ។ បុរសទាំង៤ នាក់បានប្រាប់កូនប្រុសរបស់លោក ថាឱ្យឪពុករបស់គាត់ប្រុងប្រយ័ត្នបន្ថែម ។

ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨

## ការប្រជុំសហគមន៍ជនជាតិដើមភាគតិចត្រូវបានរារាំង

លោក ឌិន ខន្ទី អ្នកសម្របសម្រួលសមាគមអាដហុក ប្រចាំខេត្តរតនគិរី ត្រូវបានអាជ្ញាធរមូលដ្ឋានចុះឃ្លាំមើល និងថតរូប នៅពេលលោកកំពុងបើកវគ្គបណ្តុះបណ្តាលអំពីសិទ្ធិមនុស្ស និងច្បាប់ដែលពាក់ព័ន្ធ ជាមួយសហគមន៍ជនជាតិដើមភាគតិចក្នុងភូមិ ។ លោក គិត ចេម ជាប្រធានក្រុមប្រឹក្សាឃុំបានបញ្ជាឱ្យមេភូមិចំនួន ៤ នាក់មកពីភូមិផ្សេងគ្នា នៅក្នុងស្រុកលំផាត់ ទៅរារាំងលោក ខន្ទី មិនឱ្យរៀបចំកម្មវិធី និងហាមឃាត់អ្នកភូមិមិនឱ្យចូលរួមវគ្គបណ្តុះបណ្តាលនេះផងដែរ ។

ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨

## ការប្រជុំរបស់អ្នកឃ្លាំមើលសិទ្ធិមនុស្សត្រូវបានរារាំង

បុគ្គលិកសិទ្ធិមនុស្សសមាគមអាដហុកប្រចាំខេត្តកំពង់ចាម ត្រូវបានមេភូមិ ក៏ដូចជាអាជ្ញាធរឃុំ ស្រុករារាំងមិនឱ្យធ្វើការប្រជុំជាមួយអ្នកតំណាងសហគមន៍មូលដ្ឋានជាង ២៣ នាក់ នៅទីរួមខេត្ត ។ តំណាងសហគមន៍ទាំងនោះ បានរំពឹងថាពួកគេនឹងបានពិភាក្សាអំពីដំណោះស្រាយចំពោះជម្លោះដីធ្លីដំរ៉ាំរ៉ៃ នៅការិយាល័យអាដហុក ខេត្តកំពង់ចាម ផ្ទុយទៅវិញពួកគេត្រូវបានហាមឃាត់នៅថ្នាក់មូលដ្ឋាន ដោយពួកគេមិនបានជូនដំណឹងទៅអាជ្ញាធរចំពោះការប្រជុំរបស់ពួកគេ ។

ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨

## អ្នកការពារសិទ្ធិមនុស្សត្រូវបានសាកសួរដោយនគរបាល

អ្នកធ្វើការងារផ្នែកសិទ្ធិមនុស្សចំនួន ៤ នាក់មកពីអង្គការ លីកាដូ ត្រូវបានអាជ្ញាធរបំភិតបំភ័យ និងនាំពួកគាត់ទៅកាន់ប៉ុស្តិ៍នគរបាលឃុំនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ ដើម្បីធ្វើការសាកសួរតាមបញ្ជារបស់លោកមេនគរបាលប៉ុស្តិ៍ឃុំ ។ អ្នកទាំង៤ បានទៅចែកសម្ភារៈជំនួយដែលជាផ្នែកមួយនៃគម្រោងសេវាសង្គមរបស់អង្គការ លីកាដូ ដល់គ្រួសារចំនួន ១៧ គ្រួសារដែលរងគ្រោះដោយជម្លោះដីធ្លីជាមួយក្រុមហ៊ុន អិម ឌី អេស ដែលម្ចាស់ដីសម្បទានចំកៅស៊ូនេះជាកម្មសិទ្ធិរបស់លោកឧកញ៉ា ទ្រី ភាព ។ អ្នកការពារសិទ្ធិមនុស្សទាំង៤នាក់ នោះត្រូវបានចោទប្រកាន់ថាបានចែកសម្ភារៈជំនួយទាំងនោះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

## តំណាងសហគមន៍ត្រូវបានសាកសួរជុំវិញយុទ្ធនាការអធិបតេយ្យភាពស្បៀងអាហារ

លោក សឹង សុខុម តំណាងសហគមន៍មកពីស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ត្រូវបានកោះហៅទៅប៉ុស្តិ៍នគរបាលឃុំតាមបទបញ្ជារបស់ស្នងការរងស្រុកលោក ប្រាក់ មូល បន្ទាប់ពីលោក សុខុម និងសមាជិកសហគមន៍មូលដ្ឋានចំនួន ២៥ នាក់ផ្សេងទៀត បានប្រារព្ធពិធីអបអរសាទរយុទ្ធនាការ ១៦ ថ្ងៃនៃសកម្មភាពជាសកលលើកកម្ពស់អធិបតេយ្យភាពស្បៀងអាហារ និងកសិកម្ម ។ អ្នកតំណាងត្រូវបានដោះលែងវិញ បន្ទាប់ពីការផ្តិតមេដៃលើកំណត់ហេតុរបស់នគរបាល ។

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨

## ការហែរក្បួនស្តីពីសិទ្ធិដីធ្លីត្រូវបានបញ្ឈប់ ហើយតំណាងសមាគមន៍ត្រូវបានចាប់ខ្លួន

មនុស្សប្រមាណ ៣០នាក់រួមទាំងសកម្មជនដីធ្លីសហគមន៍មកពីខេត្តកោះកុង និងអតីតសមាជិកសហគមន៍បឹងកក់ត្រូវបានរារាំងដោយសន្តិសុខខណ្ឌ ។ តំណាងសហគមន៍ ៣ នាក់គឺ លោកស្រី ស៊ី ណារ៉េត លោកស្រី ប្រាយ នីម និងលោកស្រី ព្រាប រដ្ឋា ត្រូវបានចាប់ខ្លួននិងនាំខ្លួនទៅកាន់អធិការដ្ឋាននគរបាលស្រុក ដើម្បីសាកសួរបន្ទាប់ពីអ្នកទាំងនោះព្យាយាមហែរនាំញត្តិទៅការិយាល័យខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដោយអំពាវនាវដល់សម្តេចនាយករដ្ឋមន្ត្រី ជួយអន្តរាគមន៍ដើម្បីបញ្ចប់រឿងវិវាទដីធ្លីរបស់ពួកគេ ។

ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

## ការប្រជុំស្តីពីសិទ្ធិដីធ្លីត្រូវបានរារាំង

អ្នកសម្របសម្រួលសមាគមអាដហុកប្រចាំខេត្តកំពង់ចាម ត្រូវបានរារាំងមិនឱ្យបើកកិច្ចប្រជុំជាមួយតំណាងសហគមន៍មូលដ្ឋានចំនួន ២៣ នាក់នៅទីរួមខេត្ត ដោយលោកមេភូមិ និងនគរបាលឃុំ/ស្រុក ។ តំណាងសហគមន៍ដែលសង្ឃឹមថា នឹងបានពិភាក្សាអំពីដំណោះស្រាយវិវាទដីធ្លីដំរ៉ាំរ៉ៃ នៅការិយាល័យសមាគមអាដហុកខេត្តកំពង់ចាម ត្រូវបានរារាំង ដោយអាជ្ញាធរលើកហេតុផលថា ពួកគេមិនបានជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានអំពីការប្រជុំរបស់ពួកគេ។

ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

## អ្នកសម្របសម្រួលអង្គការសិទ្ធិមនុស្ស ត្រូវបានបំភិតបំភ័យ

បុគ្គលិកអាដហុកត្រូវបានបំភិតបំភ័យ និងឃ្លាំមើលពីសំណាក់អាជ្ញាធរ ឃុំ ស្រុក ខណៈពេលកំពុងជាប់ពិភាក្សាជាមួយនឹងតំណាងសហគមន៍មកពី ០៧ សហគមន៍ដែលជាប់គាំងក្នុងជម្លោះដីធ្លីដំរ៉ាំរ៉ៃ ។ តំណាងសហគមន៍បានមកកាន់ការិយាល័យអាដហុកខេត្ត កំពង់ចាម ដើម្បីជជែកអំពីដំណោះស្រាយសំខាន់ៗក្នុងជម្លោះ និងដើម្បីទទួលការហ្វឹកហាត់អំពីប្រើប្រាស់ទូរស័ព្ទដៃ ដើម្បីជួយពួកគេដល់ការតស៊ូមតិដើម្បីសហគមន៍របស់ពួកគេ ។ អាជ្ញាធរមូលដ្ឋានបានថតរូបអ្នកចូលរួម និងព្រមានថាអ្នកទាំងនោះត្រូវជូនដំណឹងដល់អាជ្ញាធរ មុនពេលបើកកិច្ចប្រជុំ ។

ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩

## អ្នកតំណាងសហគមន៍ដីធ្លីត្រូវបានគំរាមកំហែង

អ្នកតំណាងសហគមន៍ដីធ្លីចំនួន ៤ នាក់រួមមានលោក ហម ណៃ លោក រ៉ុ សាន លោក សៃយ តាយ និងលោក ស្រុក ឡាង នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ត្រូវបានកោះហៅទៅសាលាឃុំទន្លូង ដើម្បីសាកសួរជុំវិញរឿងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃជាមួយអ្នកជំនួញឈ្មោះ ឈុន សាវុធ ។ អ្នកតំណាងទាំង ៤ នាក់ត្រូវបានបង្ខំឱ្យផ្តិតមេដៃលើកិច្ចសន្យាយល់ព្រមមិនរៀបចំការតវ៉ានៅតាមសហគមន៍ឬការប្រមូលផ្តុំគ្នា ពុំនោះទេអាជ្ញាធរនឹងចាត់វិធានការតាមផ្លូវច្បាប់ ។

ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩

## តំណាងអ្នកភូមិត្រូវបានរងការវាយដំ និងឃុំខ្លួន

លោក ម៉ុក ហេង និងលោក ជឹម ជួន ជាតំណាងអ្នកភូមិមកពីស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ត្រូវបាននគរបាលចាប់ខ្លួន និងវាយដំដោយខុសច្បាប់ មុនពេលបញ្ជូនទៅសាកសួរនៅស្នងការដ្ឋានខេត្ត ។ បុរសទាំងពីរត្រូវបានបង្ខំឱ្យផ្តិតមេដៃលើឯកសារបង្វែរដីរបស់ពួកគេ ហើយរងការគំរាមចាប់ដាក់គុកប្រសិនបើពួកគេនៅតែបន្តតវ៉ាប្រឆាំងនឹងការដណ្តើមយកដីធ្លីឆ្នាំ ២០១៦ ដែលដីស្រែជិត ១.២០០ ហិកតាកាន់កាប់ដោយ ៥៨៦ គ្រួសារ ត្រូវបានរឹបអូសនិងឈូសឆាយ ដើម្បីធ្វើជាដីសម្បទានសង្គមកិច្ចដែលឧបត្ថម្ភថវិកាដោយមូលនិធិដោយធនាគារពិភពលោក ។ អ្នកតំណាងម្នាក់ទៀត ឈ្មោះ អៀង សុខម៉េង ត្រូវបានចាប់ខ្លួនកាលពីខែមិថុនា និងត្រូវបានចោទប្រកាន់ពីបទបង្ករបួសស្នាមដោយចេតនា ។

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩

## ព្រះចៅអធិការវត្តត្រូវបានចាប់ផ្សឹក ដោយសារព្រះអង្គប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិ

ព្រះតេជគុណ ហ៊ រ សុខុន ព្រះចៅអធិការវត្តច្បារអំពៅនៅរាជធានីភ្នំពេញ ត្រូវបានបង្ខំអោយសឹកដោយមន្រ្តីជាន់ខ្ពស់របស់ក្រសួងធម្មការនិងសាសនា មុនពេលកម្លាំងចម្រុះរបស់មន្ត្រីនគរបាលជាង ៥០ នាក់បានមកដល់តាមបញ្ជារបស់លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ។ ព្រះតេជគុណ សុខុន បានបង្ហោះខ្លឹមសារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដោយរិះគន់រដ្ឋាភិបាលក្នុងការខកខាន មិនបានរក្សាការអនុគ្រោះពន្ធនាំចូលទំនិញទៅកាន់សហភាពអឺរ៉ុបដោយមិនគិតពន្ធ តាមរយៈកម្មវិធីពាណិជ្ជកម្ម អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ (EBA) ដោយសារតែការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមាននៅកម្ពុជា ។

ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩

## ការប្រារព្ធទិវានារីអន្តរជាតិត្រូវបានរារាំង

ប្រជាជនជាង ៦០ នាក់មកពីសហគមន៍ចំនួន ៤ ផ្សេងគ្នានៅទូទាំងស្រុកមេមត់ ខេត្តកំពង់ចាម ត្រូវបានរារាំង មិនឱ្យប្រារព្ធទិវានារីអន្តរជាតិដោយអភិបាលស្រុកមេមត់លោក ឆេង ប៊ុណ្ណា ដែលរួមជាមួយមន្ត្រីឃុំដោយបានអះអាងថាសហគមន៍មិនបានជូនដំណឹងអំពីផែនការរបស់ពួកគេជាមួយអាជ្ញាធរមូលដ្ឋាន ។ តំណាងសហគមន៍ទន្លូងលោក យ៉ែម គង់ រងការគំរាមកំហែងដាក់គុក ប្រសិនបើការប្រារព្ធពិធីនេះប្រព្រឹត្តទៅដូចការគ្រោងទុក ។

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩

## និពន្ធនាយកទទួលការគំរាមកំហែងសម្លាប់ ដោយសារអត្ថបទរឿងក្នុងកាសែត

និពន្ធនាយកកាសែតលោក ផ្លុង រ៉េត ដែលស្ថិតនៅខេត្តសៀមរាប ទទួលការគំរាមកំហែងដល់អាយុជីវិតបន្ទាប់ពីគាត់ផ្សព្វផ្សាយរឿងរ៉ាវចោទប្រកាន់ថាលោកមេឃុំម្នាក់បានលក់ដីទៅឱ្យអ្នកជំនួញ ។ លោក រ៉េត ត្រូវបានគេបញ្ជាឱ្យកែសម្រួលរឿងរ៉ាវដែលបានផ្សព្វផ្សាយដើម្បីលុបចោលការចោទប្រកាន់ ។

ថ្ងៃទី២៥ ខែមេសា
ឆ្នាំ២០១៩

## តំណាងសហគមន៍ត្រូវបានសាកសួរលើញត្តិ

តំណាងសហគមន៍ម្នាក់ ត្រូវបានកោះហៅមកសាកសួរនៅប៉ុស្តិ៍នគរបាលឃុំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បន្ទាប់ពីលោកប្រមូលស្នាមមេដៃរបស់អ្នកភូមិលើញត្តិពាក់ព័ន្ធនឹងជម្លោះដីធ្លី និងបានចែករំលែកបទចម្រៀង "សង្គមនេះ" លើបណ្ដាញសង្គមដែលជាចម្រៀងរបស់អ្នកចម្រៀងរ៉េប ឈុន ឌីមី អាយុ ២៤ឆ្នាំ ដែលបានច្រៀងរៀបរាប់និងរិះគន់យ៉ាងខ្លាំងពីភាពអយុត្តិធម៌សង្គមនៅទូទាំងប្រទេសកម្ពុជា ។

ថ្ងៃទី១៣ ខែឧសភា
ឆ្នាំ២០១៩

## អ្នកចម្រៀងរ៉េបត្រូវបានបំភិតបំភ័យ ដោយសារតែបទចម្រៀងរ៉េបដ៏ល្បីល្បាញ

អ្នកចម្រៀងរ៉េបឈ្មោះ ឈុន ឌីមី អាយុ ២៤ឆ្នាំ ត្រូវបានមន្ត្រីនគរបាលពីរនាក់នៅខេត្តសៀមរាប ទាមទារមើលសំបុត្រកំណើត សំបុត្រការងារ និងសៀវភៅគ្រួសារ ។ ថ្មីៗនេះលោក ឌីមី បានចេញបទចម្រៀងមួយដែលមានចំណងជើងថា "សង្គមនេះ" ដែលបង្ហាញនូវភាពអយុត្តិធម៌ក្នុងសង្គមដែលមានដូចជាអំពើពុករលួយ ស្ថានភាពសហគមន៍ក្រីក្រនិងជម្លោះដីធ្លីដែលកំពុងកើតមាន ។ ក្រោយមកលោក ឌីមី បានលុបបទចម្រៀងនោះចេញពីគណនីបណ្ដាញសង្គមរបស់គាត់ ។

ថ្ងៃទី២៨ ខែឧសភា
ឆ្នាំ២០១៩

## បុគ្គលិកផ្នែកសិទ្ធិមនុស្សទទួលរងការគំរាមកំហែងពីសំណាក់អាជ្ញាធរ

បុគ្គលិកសិទ្ធិមនុស្សសមាគមអាដហុក ត្រូវបានគំរាមកំហែងពីសំណាក់អាជ្ញាធរឃុំ តាមរយៈទូរស័ព្ទ បន្ទាប់ពីបានធ្វើការប្រជុំពិភាក្សាជាមួយ សមាជិកសហគមន៍ ៣៨នាក់ ដើម្បីពិភាក្សាអំពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។

ថ្ងៃទី០៤ ខែ មិថុនា
ឆ្នាំ២០១៩

## សកម្មជនដីធ្លីម្នាក់ជាប់ឃុំខ្លួន ក្រោយផ្ដល់បទសម្ភាសន៍ទៅសារព័ត៌មាន

សកម្មជនដីធ្លីម្នាក់ឈ្មោះ ថៃ ថេន ត្រូវបានអាជ្ញាធរកងរាជអាវុធហត្ថខេត្តចាប់ខ្លួន នៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ និងបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារខេត្ត ក្រោយពេលដែលលោកបានផ្ដល់បទសម្ភាសន៍ឱ្យវិទ្យុអាស៊ីសេរី ។ ដីកាចាប់ខ្លួនត្រូវបានធ្វើឡើងក្រោយពីទទួលបានពាក្យបណ្ដឹងពីលោក ខម សារឿន អតីតទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង ។ កាលពីថ្ងៃទី ១២ ខែមីនា លោក ថេន រាយការណ៍ពីទុក្ខលំបាករបស់អ្នកភូមិ ដែលមិនមានទឹកស្រោចស្រពស្រែរបស់អ្នកទាំងនោះ ។

ថ្ងៃទី០៩ ខែ កក្កដា
ឆ្នាំ២០១៩

## សកម្មជនជាច្រើននាក់ត្រូវបានចាប់ខ្លួនក្នុងពិធីបុណ្យរំលឹកខួបនៃការស្លាប់របស់លោកបណ្ឌិត កែម ឡី

សកម្មជនលោក គង់ រ៉ៃយា មានអាយុ ២៨ឆ្នាំ រួមជាមួយភរិយារបស់គាត់ និងសមាជិកគ្រួសារ ២នាក់ផ្សេងទៀត ត្រូវបានចាប់ខ្លួនដោយសមត្ថកិច្ចក្រុងចំនួន១០នាក់ បន្ទាប់ពីលោកបានផ្សព្វផ្សាយនៅលើបណ្ដាញសង្គមហ្វេសប៊ុក អំពាវនាវលក់អាវយឺតដែលមានរូបលោកបណ្ឌិត កែម ឡី ។ លោក រ៉ៃយ៉ា ក៏បានបង្ហោះសារអំពី លេខទូរស័ព្ទអ្នកបើកបររថយន្តឈ្នួលម្នាក់ ដែលអាចដឹកមនុស្សទៅ រាជធានីភ្នំពេញដើម្បីចូលរួមក្នុងពិធីបុណ្យរំលឹកខួបនៃការបាញ់សម្លាប់លោកបណ្ឌិត កែម ឡី ផងដែរ ។ ក្រោយមកលោក រ៉ៃយា ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យបង្កចលាចលក្នុងសង្គម ។ ថ្ងៃបន្ទាប់សកម្មជនបរិស្ថានពីរនាក់ គឺ លោក ជុំ ហួត និងលោក ជុំ ហួរ រួមជាមួយនឹងលោក សួង នាគព័ន្ធ ជាអនុប្រធានក្រុមសម្ព័ន្ធយុវជននិស្សិតបញ្ញាវ័ន្តខ្មែរ ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ។ អ្នកទាំងបីនោះបានចូលរួមជាមួយសកម្មជនយុវជនដ៏ទៃទៀត ក៏ដូចជាមេដឹកនាំសហជីព និងសមាជិកសង្គមស៊ីវិល ដើម្បីប្រារព្ធពិធីរំលឹកខួប៣ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី នៅស្ថានីយប្រេងឥន្ធនៈកាល់តិចបូកគោក្នុង ខណ្ឌចំការមនរាជធានីភ្នំពេញ ។ លោក នាគព័ទ្ធ ដែលបានចែកខិត្តប័ណ្ណអំពាវនាវឱ្យបញ្ឈប់ការសម្លាប់ក្រៅប្រព័ន្ធតុលាការ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ។



តំណាងសហគមន៍ជីខក្រោម អ្នកស្រី ផាវ ញើង ចូលរួមបាតុកម្មនៅខាងក្រៅក្រសួងដែនដីនគរូបនីយកម្មនៅភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ២០២០

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩

## អ្នកសារព័ត៌មាន និងពលរដ្ឋមួយចំនួនត្រូវបានចោទប្រកាន់ពាក់ព័ន្ធជុំវិញបញ្ហាជម្លោះដីធ្លី

មនុស្សបីនាក់ ក្នុងនោះមានអ្នកសារព័ត៌មានមកពីស្រុក ជលគីរី ខេត្ត កំពង់ធំ ត្រូវបានមន្ត្រីអាជ្ញាធរស្រុក លោក ហៃ មនោរម្យ ប្ដឹងពីបទបរិហារបង្កាច់កេរ្ដិ៍ និងញុះញង់ឱ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍ ។ មនុស្សបីនាក់នោះរួមមានឈ្មោះ លោក សុខ ឧត្តម អ្នកសារព័ត៌មាននិងជានាយកវិទ្យុរឹទ្ធិសែន និងពលរដ្ឋពីរនាក់ផ្សេងៗទៀតឈ្មោះ អ៊ុង ប៉ុយ និង ព្រី ឡៃស៊ីន ដែលអ្នកទាំងបីជាក្លាយគោលដៅ ទាក់ទងទៅនឹងបញ្ហាទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃនៅក្នុងភូមិ ព្រៃគ្រីត្បូង ។

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩

## អ្នកសារព័ត៌មាន និងសកម្មជនដីធ្លីជាច្រើននាក់ត្រូវបានចាប់ខ្លួន

អ្នកសារព័ត៌មានក្នុងស្រុក ០២នាក់ ដែលម្នាក់មានឈ្មោះ ហ៊ុន សុខា ជាប្រធានក្លឹបអ្នកកាសែតឯករាជ្យ និងម្នាក់ទៀតឈ្មោះ កែវ រតនា ជាការីនិពន្ធកាសែត TN និងសមាជិកសហគមន៍ ៥នាក់ នៅ ស្រុកព្រះសីហនុ ខេត្តព្រះសីហនុ ត្រូវបានកងរាជអាវុធហត្ថចាប់ខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ខណៈពេលដែលសមាជិកសហគមន៍កំពុងធ្វើការតវ៉ារារាំងមិនឱ្យធ្វើការឈូសឆាយលើដីកំពុងមានទំនាស់ជាមួយប្រជាពលរដ្ឋ ២៤ គ្រួសារ ដែលការចាប់ខ្លួននេះធ្វើឡើងក្រោមការបង្គាប់បញ្ជារបស់ ឧកញ៉ា ខូវ សម្បត្តិ ។ អ្នកសារព័ត៌មានទាំងពីរត្រូវបានដោះលែងវិញ ក្រោយពេលធ្វើការសាកសួរចម្លើយរួច ។

ថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០១៩

## ប្រជាពលរដ្ឋបុរីកីឡាជាច្រើនអ្នកត្រូវបានឃុំខ្លួនដោយខុសច្បាប់

ប្រជាពលរដ្ឋបុរីកីឡាចំនួន១៧នាក់ ដែលធ្លាប់រស់នៅលើអគារបុរីកីឡាស្ថិតនៅរាជធានីភ្នំពេញ ត្រូវបានចាប់និងឃុំខ្លួនដោយខុសច្បាប់ជាច្រើនម៉ោងនៅសាលាខណ្ឌ៧មករា ក្រោមការបង្គាប់បញ្ជាពីអភិបាលរងរាជធានីភ្នំពេញ លោក មាន ច័ន្ទយ៉ាដា ។ ប្រជាពលរដ្ឋបុរីកីឡាធ្លាប់បានធ្វើការតវ៉ាអហិង្សា ដើម្បីអំពាវនាវរកដំណោះស្រាយលើការផ្ដល់សំណងដល់ពួកគាត់ចំពោះការបណ្ដេញចេញដោយបង្ខំ និងការតវ៉ារារាំងការវាយកម្ទេចអគារបុរីកីឡាចាស់ចោល ។ ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួន ១៧នាក់ ក្នុងនោះមានប្រជាពលរដ្ឋបុរីកីឡាចំនួន ៥នាក់ ត្រូវបានបញ្ជូនទៅដាក់នៅ មណ្ឌលស្ដារនីតិសម្បទាព្រៃស្ពឺ អស់រយៈពីរថ្ងៃ ។ ប្រជាពលរដ្ឋ១៧នាក់ ត្រូវបានដោះលែងវិញក្រោយពេលពួកគាត់ត្រូវបានសាកសួររួច និងផ្ដិតមេដៃលើកិច្ចសន្យា ដែលសន្យាមិនធ្វើបាតុកម្មដូចនេះម្ដងទៀតទេ ។

ថ្ងៃទី០៤ ខែ តុលា ឆ្នាំ២០១៩

## ព្រះសង្ឃទទួលការគំរាមកំហែងទាក់ព័ន្ធនឹងសកម្មភាពបរិស្ថាន

ព្រះសង្ឃមួយអង្គដែលគង់នៅវត្តក្នុងព្រៃមួយកន្លែងស្ថិតក្នុងខេត្ត កំពង់ស្ពឺ ត្រូវបានជនមិនស្គាល់មុខគំរាមកំហែង ដោយប្រើប្រាស់កាំភ្លើងបាញ់ទៅតាមសសរវិហារវត្ត ។ ព្រះតេជគុណ ធ្លាប់បានចូលរួមសកម្មភាពបរិស្ថានជាមួយចលនាមាតាធម្មជាតិ និងការពារព្រៃឈើ និងសត្វព្រៃនៅតំបន់ដែលព្រះអង្គគង់នៅ ។ ព្រះតេជគុណធ្លាប់ប្រទះឃើញសារគំរាមមួយនៅជាប់នឹងដើមឈើ ដែលខ្លឹមសារនៃសារនោះបានព្រមានថា "បើមានអាសង្ឃពាល គ្មានទេសេចក្ដីសុខ គ្មានទេសន្តិភាព" ។

ថ្ងៃទី០៩ ខែ វិច្ឆិកា ឆ្នាំ២០១៩

## អ្នកសារព័ត៌មានត្រូវបានឃាត់ខ្លួនជុំវិញការវិលត្រលប់របស់លោក សម រង្ស៊ី

អ្នកសារព័ត៌មានរបស់វិទ្យុសម្លេងប្រជាធិបតេយ្យ VOD ចំនួន២នាក់ គឺ លោក វ៉ាន់ វិចារ និង លោក ឆន ចាន់រ៉ែន ត្រូវបានចាប់និងឃុំខ្លួនអស់រយៈពេល ៣ម៉ោងនៅឯទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត ខណៈពេលដែលអ្នកសារព័ត៌មានទាំងពីរូបនោះកំពុងឈរយកការណ៍នៅឯច្រកទ្វារអន្តរជាតិប៉ោយប៉ែត ត្រង់ចំណុចដែលលោកសមរង្ស៊ីគ្រោងនឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញតែមិនបានជោគជ័យ ។ អ្នកសារព័ត៌មានទាំងពីរ ត្រូវបានដោះលែងបន្ទាប់ពីបានផ្ដិតមេដៃលើកំណត់ហេតុសាកសួរចម្លើយរបស់មន្ត្រីនគរបាល ។

ថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០១៩

## ប្រជាពលរដ្ឋនៅក្នុងសហគមន៍ទទួលការគំរាមកំហែងជុំវិញការរៀបចំទិវាសិទ្ធិមនុស្ស

តំណាងសហគមន៍ម្នាក់ បានរងការគំរាមចាប់ខ្លួនពីសំណាក់ស្នងការរងនគរបាល ខេត្តព្រះសីហនុ បន្ទាប់ពីមានមនុស្សប្រមាណជាង ១០០នាក់ មកពី ១០សហគមន៍ផ្សេងៗគ្នា ដែលក្នុងនោះ ៦ សហគមន៍ជាសហគមន៍រងគ្រោះដីធ្លី បានជួបជុំគ្នានៅមុខសាលាខេត្តព្រះសីហនុ ដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ធ្នូ ។ សមាជិកសហគមន៍ទាំងនោះ ដែលជាប់គាំងក្នុងបញ្ហាទំនាស់ដីធ្លី បានរួមគ្នាផ្តិតមេដៃលើញត្តិរួមមួយ អំពាវនាវឱ្យអាជ្ញាធរមូលដ្ឋានជួយពន្លឿនការដោះស្រាយបញ្ហាដីធ្លីជូនពួកគាត់ ។

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩

## តំណាងសហគមន៍រងការបង្ខិតបង្ខំពាក់ព័ន្ធនឹងការផ្សាយរបស់វិទ្យុ

តំណាងសហគមន៍ម្នាក់ ត្រូវបានអាជ្ញាធរបង្ខំឲ្យផ្តិតមេដៃលើកិច្ចសន្យាបញ្ឈប់ការចាក់ផ្សាយរបស់វិទ្យុអាស៊ីសេរីជាសាធារណៈបន្តទៀត ក្រោយពេលគាត់បានចាក់ផ្សាយតាមមេក្រូ នៅពេលមានការជួបជុំសហគមន៍នៅ សាលាបុណ្យភូមិមួយកន្លែងស្ថិតនៅខេត្តកំពង់ឆ្នាំង ។ លោក និងអ្នកតំណាងសហគមន៍មួយរូបទៀត ក៏បានទទួលរងការព្រមានមិនឱ្យរៀបចំដឹកនាំសហគមន៍ដើម្បីប្រារព្ធពិធីសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូផងដែរ ។

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩

## អ្នកសារព័ត៌មានម្នាក់ត្រូវបានកោះហៅ ដើម្បីសាកសួរទាក់ទិននឹងការចេញផ្សាយព័ត៌មាន

លោក ទៀវ សំអុល តួនាទីជាអ្នកសារព័ត៌មានរបស់គេហទំព័រថ្ងៃថ្មី ត្រូវបានអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត កោះហៅដើម្បីធ្វើការសាកសួរចម្លើយ បន្ទាប់ពីទទួលបានពាក្យបណ្តឹងពី ឧកញ៉ា ឡាច ប៊ុនលី ដែលជាអ្នកមានអំណាចម្នាក់ ។ ការប្តឹងនេះទាក់ទងទៅនឹងការចុះផ្សាយអត្ថបទព័ត៌មានលើរឿងទំនាស់ដីធ្លីមួយកន្លែងស្ថិតនៅ សង្កាត់ ផ្សារកណ្តាល រវាង ឧកញ៉ា ឡាច ប៊ុនលី និង ស្ត្រីដែលជាពលរដ្ឋម្នាក់ឈ្មោះ សៀម ផល្លី ។

ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

## មេដឹកនាំសហជីពទទួលរងការឃាយីពីសំណាក់អាជ្ញាធរ

លោក សុខ គីន ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC) ត្រូវបានឃាយីដោយអាជ្ញាធរមូលដ្ឋាន ក្រោមការបង្គាប់របស់អភិបាលខណ្ឌសែនសុខ លោក មូរ ម៉ានី ខណៈពេលមានការប្រជុំមួយជាមួយអង្គការម្ចាស់ជំនួយ និងក្រុមការងារនៅក្នុងការិយាល័យរបស់គាត់នៅរាជធានីភ្នំពេញ ។ អាជ្ញាធរបានទាមទារចង់ដឹងពីមូលហេតុនៃការប្រជុំ ហើយបានចោទប្រកាន់ លោក គីន ចំពោះការមិនសុំអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន និងបញ្ចុះបញ្ចូលឱ្យអ្នកតំណាងសហជីពរូបនេះចូលបម្រើការងារនៅក្នុងជួរគណបក្សកាន់អំណាច ។

ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០

## ការបំភិតបំភ័យទៅលើសកម្មជនបរិស្ថានចលនាមាតាធម្មតា

សកម្មជនចលនាមាតាធម្មជាតិចំនួន ០៣នាក់ រួមមានឈ្មោះ ថុន រដ្ឋា ប៊ិញ ពិសិទ្ធ និង សិទ្ធ ជីវលីម៉េង ត្រូវបានឃាត់ខ្លួន និងគំរាមកំហែងដោយអាជ្ញាធរខណ្ឌចំការមន ខណៈពេលដែលអ្នកទាំងបីកំពុងផលិតវីដេអូទាក់ទងទៅនឹងទីតាំងដែលរក្សាទុកភ្លុកដំរី និងឆ្អឹងសត្វព្រៃកម្រផ្សេងៗទៀតដែលសមត្ថកិច្ចបានចាប់ និងរឹបអូសទុកនាពេលកន្លងមកនៅក្នុងរាជធានីភ្នំពេញ ។ អធិការរងនគរបាលខណ្ឌ លោក ជុន ប៊ុនណាន បានដកហូតយកអង្គចងចាំ (memory) ចេញពីកាមេរ៉ាដែលពួកគេបានថត ហើយបានដោះលែងសកម្មជនវ័យក្មេងទាំងបីនាក់នេះ ក្រោយពេលពួកគេបានផ្តិតមេដៃព្រមព្រៀងលើកិច្ចសន្យាបញ្ឈប់សកម្មភាពរបស់ពួកគេ ។

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

## តំណាងសហជីពម្នាក់ត្រូវបានវាយដោយបំពង់ដែកទីប

លោក សឿង ប្រុស រងរបួសយ៉ាងធ្ងន់ធ្ងរ ក្រោយត្រូវបានជនមិនស្គាល់អត្តសញ្ញាណចំនួនបីនាក់ជិះម៉ូតូ យកបំពង់ដែកទីបវាយក្បាលជនរងគ្រោះពីក្រោយ បណ្តាលឱ្យបែកក្បាលហូរឈាម ខណៈពេលដែលជនរងគ្រោះឈរទិញបាយហូបនៅមុខរោងចក្រ ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០

## អ្នកអភិរក្សជាច្រើននាក់ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់

បុគ្គលិកស្ម័គ្រចិត្តអង្គការការពារ និងអភិរក្សសត្វព្រៃឈើជលផលកម្ពុជា ចំនួន១០នាក់ ត្រូវបានឃាត់ខ្លួនដោយខុសច្បាប់ពីសំណាក់ប៉េអឹមខេត្តក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ខណៈពួកគេកំពុងធ្វើការឃ្លាំមើលលើសកម្មភាពបូមខ្សាច់នៅជិតស្ពានព្រែកទឹកសាបនៃខេត្តព្រះសីហនុ ។ បន្ទាប់ពីរងការឃុំខ្លួនបណ្ដោះអាសន្នរយៈពេល ៨ខែ មក អ្នកទាំងនោះ ត្រូវបានតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារ ២ឆ្នាំប៉ុន្តែទោសសល់ពីការឃុំខ្លួនបណ្ដោះអាសន្នត្រូវព្យួរ ។

ថ្ងៃទី២១ ដល់ ២២ ខែកុម្ភៈ ឆ្នាំ២០២០

## សហគមន៍ព្រៃឡង់ ត្រូវបានរារាំង មិនឱ្យធ្វើពិធីបំបួសដើមឈើ

មនុស្សជាង ២០០នាក់ រួមមាន ព្រះសង្ឃ សមាជិកសហគមន៍ និងសកម្មជនបរិស្ថានមកពីបណ្ដាញសហគមន៍ព្រៃឡង់ដែលមកពីខេត្ត ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង និងក្រចេះ ត្រូវបានមន្ត្រីនគរបាលប្រដាប់អាវុធ និងមន្ត្រីបរិស្ថានរារាំង ខណៈដែលពួកគេកំពុងធ្វើដំណើរតាមផ្លូវចូលទៅក្នុងព្រៃ ដើម្បីប្រារព្ធពិធីបុណ្យបំបួសដើមឈើ ។ តំណាងសហគមន៍ពីររូបនៅខេត្តកំពង់ធំ ត្រូវបានមន្ត្រីបរិស្ថានប្រើប្រាស់កម្លាំងបាយលើពួកគាត់ ហើយថែមទាំងគំរាមចាប់ខ្លួន ប្រសិនបើពួកគាត់នៅតែបន្តដំណើរចូលទៅក្នុងព្រៃដើម្បីប្រារព្ធពិធីដោយសន្តិវិធីក៏ដោយ ។

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០

## កសិករជាច្រើននាក់ទទួលរងការគំរាមចាប់ខ្លួន

តំណាងសហគមន៍ម្នាក់ និងបុគ្គលិកអង្គការសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) ចំនួន ០៤នាក់ ត្រូវបានរារាំងមិនឱ្យបើកវគ្គបណ្ដុះបណ្ដាលស្ដីពី សិទ្ធិមនុស្ស និងកសិកម្ម ដល់អ្នកភូមិ ៣០នាក់ នៅក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ។ បុគ្គលិកអង្គការដែលកំពុងរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការបង្កើតក្រុមសន្សំប្រាក់ត្រូវបានអនុប៉ុស្តិ៍គំរាមចាប់ខ្លួន ប្រសិនបើពួកគេនៅតែបន្តវគ្គបណ្ដុះបណ្ដាលនេះ ។

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០

## សកម្មជនបរិស្ថានជាច្រើននាក់ ត្រូវបានវាយដំ និងចាប់ខ្លួន[៩]

សកម្មជនបរិស្ថានចំនួន ៤នាក់ រួមមានលោក អ៊ួច ឡេង ដែលទទួលបានពានរង្វាន់ពិភពលោកផ្នែកបរិស្ថាន ត្រូវបានសន្តិសុខក្រុមហ៊ុន ស៊ីងបាយអូចិច (ជាក្រុមហ៊ុនខ្មែរតៃវ៉ាន់ដែលរងការចោទប្រកាន់ថាបានកាប់បំផ្លាញព្រៃឈើខុសច្បាប់) វាយដំ មុនពេលប្រគល់អ្នកទាំងនោះទៅអាជ្ញាធរក្នុងស្រុក ដើម្បីសាកសួរអស់រយៈពេលពីរថ្ងៃទៀត ។ ក្នុងអំឡុងពេលឃាត់ខ្លួន សមាជិកសហគមន៍ សកម្មជន និងព្រះសង្ឃរាប់សិបនាក់ បានប្រមូលផ្តុំគ្នាដោយអហិង្សា នៅមុខសាលាដំបូងខេត្ត ដើម្បីអំពាវនាវឱ្យដោះលែងអ្នកទាំងនោះ ។ ក្រោយមកសកម្មជនទាំងនោះត្រូវបានដោះលែង ប៉ុន្តែស្ថិតក្រោមការស៊ើបអង្កេតក្នុងនាមជាជនសង្ស័យ ។ ក្រុមហ៊ុន ស៊ីងបាយអូចិច ដែលទទួលបានដីសម្បទានចំនួន ៣៤.០០០ ហិកតា ត្រូវបានសហគមន៍មូលដ្ឋានចោទប្រកាន់ថា បានកាប់ឈើប្រណិតខុសច្បាប់នៅក្នុងតំបន់ព្រៃអភិរក្ស និងកាប់ឈើក្នុងព្រៃសហគមន៍ ។

[៩] អត្ថបទខ្លីៗរបស់លីកាដូ, “សកម្មជនបរិស្ថានត្រូវបានដោះលែង បន្ទាប់ពីមានការតវ៉ាជាច្រើនថ្ងៃ”, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០, https://www.licadho-cambodia.org/flashnews.php?perm=277&khmer

ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០

## អ្នកសារព័ត៌មានម្នាក់ត្រូវបានឃាត់ខ្លួន ក្រោយដកស្រង់ពាក្យសម្ដីរបស់សម្ដេចនាយករដ្ឋមន្ត្រី

និពន្ធនាយកនៅ TVFB និងជាអ្នកសារព័ត៌មាន លោក សុវណ្ណ រិទ្ធី ត្រូវបានចាប់ខ្លួននៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហើយបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន ដោយចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ បន្ទាប់ពីរូបលោកបានបង្ហោះសារ ដែលភ្ជាប់ជាមួយការដកស្រង់ពាក្យសម្ដីរបស់សម្ដេចនាយករដ្ឋមន្ត្រី ។ ការបង្ហោះសាររបស់លោក សុវណ្ណ រិទ្ធី គឺដកស្រង់ពាក្យសម្ដីឡើងវិញរបស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មួយឃ្លាដែលមានខ្លឹមសារថា បើអ្នករត់ម៉ូតូឌុបក្ស័យធន់ដោយសារការផ្ទុះនៃជំងឺកូវីដ១៩នេះ លក់ម៉ូតូចាយសិនទៅរដ្ឋាភិបាលគ្មានលទ្ធភាពជួយនោះទេ ។ មុនពេលដែល លោក សុវណ្ណ រិទ្ធី ត្រូវបានចោទប្រកាន់ ក្រសួងព័ត៌មានបានចេញសេចក្ដីប្រកាសលុបចោលអាជ្ញាប័ណ្ណផ្សព្វផ្សាយព័ត៌មានរបស់មជ្ឈមណ្ឌលព័ត៌មានTVFB ។ ក្រោយរយៈពេលជិតប្រាំមួយខែនៅ ក្នុងពន្ធនាគារ លោក សុវណ្ណ រិទ្ធី ត្រូវបានផ្ដន្ទាទោសពន្ធនាគារចំនួន ១៨ ខែ ហើយទោសដែលនៅសល់ពីការឃុំខ្លួនបណ្ដោះអាសន្នត្រូវព្យួរ ។

ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២០

## សកម្មជនបរិស្ថានទទួលរងការគំរាមកំហែង

ប្រធានអង្គការការពារធនធានធម្មតាជាតិ លោក ឈើយ ឧត្ដមរស្មី ជាកូនប្រុសសកម្មជនបរិស្ថានលោក ឈុត វុទ្ធីដែលត្រូវបានគេសម្លាប់ និងក្រុមយុវជនប្រមាណ ៤០នាក់ ព្រមទាំងសកម្មជនបរិស្ថានជាច្រើនរូបទៀត ត្រូវបានមន្ត្រីឧទ្យានរក្សប្រដាប់ដោយអាវុធប្រហែល ១០នាក់ បញ្ឈប់មិនឱ្យមានការជួបជុំប្រារព្ធពិធីរំឭកបុណ្យខួបនៃការបាញ់សម្លាប់លោក ឈុត វុទ្ធីនៅក្នុងព្រៃឡង់ទេ និងគំរាមចាប់ខ្លួនផងដែរ ។ មន្ត្រីប្រដាប់អាវុធទាំងនោះត្រូវបានដឹកនាំដោយលោក មាស ញឹម ប្រធានមន្ទីរបរិស្ថានខេត្ត ព្រះវិហារ រួមដំណើរជាមួយអភិបាលរងស្រុករវៀង និងមន្ត្រីសុខាភិបាលដើម្បីរារាំងពួកគេមិនឱ្យជួបជុំគ្នាទេ និងបញ្ជាក់ថាដើម្បីទប់ស្កាត់កុំឱ្យមានការឆ្លងជំងឺកូវីដ១៩ (covid-១៩) ។ ថ្ងៃបន្ទាប់ លោក ស្រី ឌឹក មេបញ្ជាការនៃកងពលធំអន្តរាគមន៍លេខ៣ បានដាក់ទាហ៊ានប្រមាណជា ៥០នាក់ចូលព្រៃឡង់ ដើម្បីតាមរកសកម្មជនបរិស្ថាន០៥នាក់ ដែលបានចូលរួមប្រារព្ធពិធីនេះជាពិសេសសកម្មជនដែលមានឈ្មោះដូចជា៖ លោក អ៊ុច ឡេង លោក ឃេម សុឃី លោក ស្រី ថី លោក ស្រី ទីន និង លោក ហេង ស្រស់ ។

ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០

## តំណាងសហគមន៍ត្រូវបានឃាត់ខ្លួនដោយសារការដាក់ញាត្តិទាក់ទងទៅនឹងជំងឺកូវីដ១៩

អ្នកស្រី នី សន្តោស អាយុ៥០ឆ្នាំ ជាតំណាងសហគមន៍ រួមជាមួយមនុស្ស០៨នាក់ផ្សេងទៀត ដែលជាតំណាងរបស់សហគមន៍ចំនួន ១៤១ ត្រូវបានឃាត់ខ្លួននិងសួរចម្លើយអស់រយៈពេល ៨ ម៉ោង នៅសាលាខណ្ឌដូនពេញ បន្ទាប់ពីពួកគាត់បានឡើងមកភ្នំពេញ ដើម្បីដាក់ញាត្តិអំពាវនាវរកជំនួយបន្ថែមពីរដ្ឋាភិបាលដល់សហគមន៍ដែលងាយរងគ្រោះ អំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ ។ អ្នកទាំង០៩នាក់ ត្រូវបានបង្ខំឱ្យផ្ដិតមេដៃលើកិច្ចសន្យាព្រមព្រៀងដើម្បីបញ្ឈប់សកម្មភាពរបស់ពួកគេ មុនពេលដែលត្រូវបានដោះលែង ។

ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០

## ព្រះសង្ឃ និងយុវជនដែលជាសកម្មជនទទួលរងការគំរាមកំហែងទាក់ទងនឹងការតវ៉ាអំពីបញ្ហាបំណុលមីក្រូហិរញ្ញវត្ថុ

សមាជិកនៃក្រុមយុវជនខ្មែរថាវរៈមួយចំនួន រួមទាំងសកម្មជនការពារសិទ្ធិមនុស្ស លោក ហ៊ុន វណ្ណៈ ត្រូវបានចាប់និងឃាត់ខ្លួនអស់ជាច្រើនម៉ោងដើម្បីធ្វើការសាកសួរចម្លើយ នៅប៉ុស្ដិ៍នគរបាលខេត្តបាត់ដំបង ពាក់ព័ន្ធនឹងការធ្វើការតវ៉ាអំពាវនាវទៅកាន់ស្ថាប័នគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដើម្បីពន្យារពេលក្នុងការបង់សងប្រាក់កម្ចីដោយសារវិបត្តិសេដ្ឋកិច្ចបណ្ដាលមកពីជំងឺកូវីដ១៩ ។ ព្រះសង្ឃចំនួន០៤អង្គ ផ្សេងទៀតត្រូវបានគំរាមកំហែងបណ្ដេញចេញពីវត្ត ប្រសិនបើព្រះអង្គនៅតែបន្តធ្វើបាតុកម្មអហិង្សាតទៅទៀត ។



កងកម្លាំងប្រដាប់ដោយអាវុធឃ្លាំមើលការជួបជុំរបស់សមាជិកបណ្ដាញ
សហគមន៍ព្រៃឡង់ប្រារព្ធពីធីបុណ្យបំបួសដើមឈើក្នុង ឆ្នាំ២០១៩

ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

## អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួនជុំវិញការតវ៉ាលើករណីរំលោភដីធ្លី

អ្នកសារព័ត៌មាននៃការសែតរីទ្ធិសែន លោក សុខ ឧត្តម ត្រូវបានចាប់ខ្លួនដោយខុសច្បាប់ពីសំណាក់មន្ត្រីនរគបាលចំនួន១០នាក់ ដែលដឹកនាំដោយស្នងការនគរបាលខេត្តកំពង់ឆ្នាំង បន្ទាប់ពីរូបលោកបានធ្វើការសម្ភាសន៍សមាជិកគ្រួសារជាង១០០គ្រួសារ ដែលដីធ្លីរបស់ពួកគេត្រូវបានរំលោភយកដោយមេបញ្ជាការយោធាជាន់ខ្ពស់ ។ លោក ឧត្តម ត្រូវបានចោទប្រកាន់ពីបទបរិហារបង្កាច់កេរ្តិ៍ និងញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅពន្ធនាគារខេត្តកំពង់ឆ្នាំង ។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០

## សកម្មជនសង្ឃមួយអង្គ បានភៀសព្រះកាយក្រោយការលាបពណ៌

ព្រះតេជគុណ លួន សុវ៉ាត ដែលជាសកម្មជនសង្ឃមួយអង្គមានភាពល្បីល្បាញ និងត្រូវបានអន្តរជាតិទទួលស្គាល់ថាជាអ្នកការពារសិទ្ធិមនុស្ស ត្រូវបានអាជ្ញាធរសង្ឃចេញលិខិតចាប់ផ្សឹកដោយប្រយោលនៅ ខេត្តសៀមរាប បន្ទាប់ពីខ្សែសំឡេងមួយបានបែកធ្លាយលើបណ្តាញសង្គមហ្វេសប៊ុក ដោយមានខ្លឹមសារចោទប្រកាន់មិនពិតថាព្រះតេជគុណ លួន សុវ៉ាត មានអំពើសេពមេថុនធម្ម (មាតុគ្រាម ឬរួមភេទ)ជាមួយនឹងស្ត្រីម្នាក់ និងកូនស្រីរបស់នាងផងដែរ ។ ព្រះតេជគុណ លួន សុវ៉ាត បានភៀសព្រះកាយទៅនៅប្រទេសអឺរ៉ុបដោយប្រើទិដ្ឋាការមនុស្សធម៌ ។ ព្រះតេជគុណត្រូវបានចោទប្រកាន់យ៉ាងគំបាំងមុខពីបទរំលោភសេន្ទវៈ ។ នៅថ្ងៃទី២៣ ខែសីហា តាមការស៊ើបអង្កេតរបស់ការសែតអន្តរជាតិញូវយ៉កថែមស៍បានបង្ហាញថា មន្ត្រីនៃអង្គភាពព័ត៌មាននិងប្រតិកម្មរហ័សដែលជាក្រុមឃោសនាផ្លូវការរបស់រដ្ឋាភិបាលកម្ពុជា គឺជាអ្នកទទួលខុសត្រូវចំពោះការបង្កើតនិងបង្ហោះវីដេអូមិនពិតនេះ ។

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០

## យុទ្ធនាការជិះកង់ត្រូវបានហាមឃាត់

សកម្មជនវ័យក្មេងមួយក្រុម រួមទាំងសកម្មជនបរិស្ថានមាតាធម្មជាតិជាច្រើននាក់ត្រូវបានកម្លាំងនគរបាលបញ្ឈប់ ខណៈពេលកំពុងជិះកង់ចេញពីខេត្តកោះកុងមករាជធានីភ្នំពេញ ដែលជាផ្នែកមួយនៃយុទ្ធនាការ "សង្គ្រោះកោះកុងក្រៅ" របស់ពួកគេ ។ មន្ត្រីនគរបាលខេត្តបានរឹបអូសយកកង់របស់យុវជនវ័យក្មេងទាំងនោះ ដើម្បីរារាំងក្រុមយុវជនពីការជិះកង់ទៅភ្នំពេញដើម្បីដាក់ញត្តិអំពាវនាវឱ្យមានការដាក់កោះដ៏ធំជាងគេនៅកម្ពុជានេះជាឧទ្យានជាតិការពារ ។ កាលពីដើមខែឧសភា មន្ត្រីនគរបាលប្រដាប់ដោយអាវុធមួយក្រុមក៏បានបំបែកបាតុកម្មអហិង្សាដែលក្រុមពួកគេបានធ្វើនៅខណ្ឌជ្រោយចង្វាររាជធានីភ្នំពេញ ហើយបានរឹបអូសយកបដានិងទង់ជាតិ ថែមទាំងគំរាមចាប់ខ្លួនអ្នកចូលរួមផងដែរ ។

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

## បាតុកម្មដោយអង្គុយសម្មាធិរបស់ព្រះសង្ឃ ត្រូវបានហាមឃាត់

ព្រះសង្ឃចំនួន ១៣អង្គ ត្រូវបានព្រះចៅអធិការវត្តបង្ខំឱ្យធ្វើកិច្ចសន្យាផ្តិតមេដៃឈប់ចូលរួមធ្វើ បាតុកម្មកូដកម្ម និងសិក្ខាសាលាក្នុងកិច្ចការសង្គម បន្ទាប់ពីមានសមត្ថកិច្ចនគរបាល និងកងរាជអាវុធហត្ថស្លៀកពាក់ស៊ីវិលប្រមាណ១០នាក់ចុះមកបំបែកការជួបជុំដោយសន្តិវិធីនៅវត្តពោធិ៍វាល ។ ព្រះតេជគុណត្រូវបានចោទប្រកាន់ថាការអង្គុយសម្មាធិ និងកាន់បដានេះគឺបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងជាការជួបជុំដោយគ្មានច្បាប់ អនុញ្ញាតិត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋាន ។

ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២០

## អ្នកសារព័ត៌មានម្នាក់ជាប់ពន្ធនាគារដោយសារការបង្ហោះសារនៅលើបណ្តាញហ្វេសប៊ុក

លោក រស់ សុឃិត ចាងហ្វាងការសែតជាតិខ្មែរត្រូវបានចាប់ខ្លួនក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនៅពន្ធនាគារព្រៃសរ ដោយចោទប្រកាន់ពីបទញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម បន្ទាប់ពីរូបលោកបានបង្ហោះសារក្នុងគេហទំព័រហ្វេសប៊ុក រិះគន់ទៅលើគណបក្សកាន់អំណាចជាហូរហែ ។ ការបង្ហោះសារជាច្រើន លើកឡើងថាសម្តេចនាយករដ្ឋមន្ត្រី មិនអាចគ្រប់គ្រងប្រទេសដើម្បីឆ្លើយតបទៅនឹងការរីករាលដាលជាសកលនៃជំងឺកូវីដ១៩ ឡើយ ។

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០

## សកម្មជនបរិស្ថានម្នាក់ត្រូវបានវាយដំនៅក្នុងវេទិកាសាធារណៈ

សកម្មជនបរិស្ថានលោក ឆន ផល្លា ត្រូវបានអ្នកភូមិមួយក្រុមវាយដំទៅលើរូបលោកនៅចំពោះមុខអាជ្ញាធរ អំឡុងពេលចូលរួមកម្មវិធីវេទិកាសាធារណៈនៅ ខេត្តរតនគិរី ដែលកម្មវិធីនេះរៀបចំដោយអភិបាលស្រុកលំផាត់ លោក នូ ថេរ ។ លោកផល្លា គឺជាមនុស្សម្នាក់ដែលតែងតែនិយាយលើកឡើងពីបញ្ហាព្រៃឈើ និងបញ្ហាទំនាស់ដីធ្លីនៅក្នុងសហគមន៍ ។ គាត់បានរាយការណ៍ថាអភិបាលរងស្រុកបានគំរាមកំហែងលោកថានឹងចាប់ដាក់គុកបើមិនព្រមបញ្ឈប់សកម្មភាពតវ៉ា និងដើរដាក់ពាក្យបណ្ដឹងពាក់ព័ន្ធរឿងព្រៃឈើ និងដីធ្លីទេ។

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០

## សកម្មជនបរិស្ថានទទួលរងការគំរាមកំហែងពាក់ព័ន្ធនឹងការឃ្លាំមើល

សមាជិកបណ្ដាញសហគមន៍ព្រៃឡង់ម្នាក់នៅខេត្តកំពង់ធំ ត្រូវបានទទួលរងការគំរាមពី មេឈ្មួញឈើដែលមានអំណាចម្នាក់ ខណៈពេលដែលកំពុងផ្តិតរូបភាពនៃការដឹកឈើខុសច្បាប់នៅពេលយប់ ។ មេឈ្មួញនោះ បានជំរិតយកទូរស័ព្ទពីសកម្មជនរូបនេះ ហើយបានដាក់ពាក្យប្ដឹងទៅកងរាជអាវុធហត្ថស្រុកទាមទារសំណងជំងឺចិត្ត ពីបទថតរូបគ្មានការអនុញ្ញាត ។

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០

## អ្នកដឹកនាំសហជីពត្រូវបានចាប់ខ្លួនជុំវិញការស៊ើបអង្កេតព្រំដែន

លោក រ៉ុង ឈុន ប្រធានសហភាពសហជីពកម្ពុជា ត្រូវបានមន្ត្រីនគរបាលចាប់ខ្លួននៅផ្ទះរបស់គាត់នាពេលយប់ថ្ងៃសុក្រ បន្ទាប់ពីគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជាបានផ្សាយជាសាធារណៈអំពាវនាវឱ្យអាជ្ញាធរចាត់វិធានការប្រឆាំងនឹងការអត្ថាធិប្បាយរបស់លោកអំពីការចុះទៅពិនិត្យមើលព្រំដែនប្រទេសកម្ពុជា-វៀតណាម កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ។ លោក រ៉ុង ឈុន សមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាដែលមិនមែនជាស្ថាប័នរបស់រដ្ឋាភិបាលបានផ្ដល់បទសម្ភាសន៍តាមវិទ្យុប៉ុន្មានម៉ោងមុនការចាប់ខ្លួនរបស់លោក ដោយបានបដិសេធថាលោកមិនបានផ្សព្វផ្សាយព័ត៌មានមិនពិតពីការបាត់បង់ដីសហគមន៍នៅតាមបណ្តោយព្រំដែន ក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈកាលពីមួយសប្តាហ៍មុននោះទេ ។

នៅព្រឹកបន្ទាប់លោករ៉ុង ឈុនត្រូវបាននាំខ្លួនទៅកាន់សាលាដំបូងរាជធានីភ្នំពេញនិងត្រូវបានចោទប្រកាន់ពី "បទញុះញង់ បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" តាមបញ្ញត្តិមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ មុនពេលត្រូវបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ នៅមណ្ឌលអប់រំកែប្រែទី១ (ម១) ដ៏ចង្អៀតណែនខ្លាំងក្នុងរាជធានីភ្នំពេញ ។ អ្នកគាំទ្ររាប់សិបនាក់បានប្រមូលផ្តុំគ្នានៅខាងក្រៅតុលាការរហូតដល់ចុងសប្តាហ៍ដើម្បីអំពាវនាវឱ្យមានការដោះលែងសហជីពរូបនេះ ទោះបីមានកងកំលាំងសន្តិសុខបញ្ជាឱ្យពួកគេបំបែកការជួបជុំក៏ដោយ ។

ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០

## ព្រះសង្ឃត្រូវបានចាប់ព្រះកាយ និងសកម្មជនដទៃទៀតជាប់ពន្ធនាគារ

ព្រះសង្ឃចំនួន ០៨អង្គ និងអតីតសកម្មជនគណបក្សប្រឆាំង ០៤ រូបទៀត ត្រូវបានមន្ត្រីនគរបាលជាង ៣០នាក់ ចាប់ខ្លួន បន្ទាប់ពីចូលរួមបាតុកម្មទាមទារឱ្យមានការដោះលែងលោក រុង ឈុន ។ ពួកគេស្ទើរតែទាំងអស់ត្រូវបានដោះលែងវិញក្រោយផ្តិតមេដៃធ្វើកិច្ចសន្យាមិនបន្តធ្វើការតវ៉ា មានតែលោក ជុំ ពុទ្ធី និងលោក ឈូ ផេង ត្រូវបានចោទពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមច្បាប់ព្រហ្មទណ្ឌ បន្ទាប់មកបានបញ្ជូនទៅឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ ក្នុងរាជធានីភ្នំពេញ ។

ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០

## អ្នកសារព័ត៌មានម្នាក់ត្រូវបានចាប់ខ្លួនក្រោយការសម្ភាសន៍

ភ្នាក់ងារយកព័ត៌មានគេហទំព័រស្នេហាជាតិ លោក កែវ ហួរ ត្រូវបានមន្ត្រីនគរបាលមួយក្រុមចាប់ខ្លួននៅទីរួមខេត្តកំពង់ឆ្នាំង បន្ទាប់ពីលោក បានសម្ភាសន៍បាតុករដែលបានប្រមូលផ្តុំគ្នាធ្វើបាតុកម្មដោយអហិង្សានៅខាងក្រៅសាលាឃុំជៀ នាដើមខែឧសភា ពាក់ព័ន្ធនឹងទំនាស់ដីធ្លី ។ គេមិនបានប្រាប់ពីមូលហេតុនៃការចាប់ខ្លួនរបស់គាត់នោះឡើយ ។ ក្រោយមក លោកត្រូវបានតុលាការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែមិនបានលើកលែងការចោទប្រកាន់នោះទេ ។

ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០

## សកម្មជនយុវជនជាច្រើននាក់ត្រូវបានចាប់ខ្លួននៅក្នុងការបង្ក្រាប

សកម្មជនយុវជនចំនួន ០៦នាក់ ត្រូវបានចាប់ខ្លួននៅរាជធានីភ្នំពេញ បន្ទាប់ពីរបន្តការទាមទារឱ្យមានការដោះលែងលោក រ៉ុង ឈុន ។ សកម្មជនយុវជន ឈឿន ដារ៉ាវី ដែលមានប្រវត្តិចូលរួមការងារយុត្តិធម៌សង្គម និងសកម្មភាពបរិស្ថានជាយូរមកហើយនោះ ត្រូវបានអូសចូលក្នុងឡានមួយដោយបានទាញសក់របស់នាង បន្ទាប់ពីនាងត្រូវបានកងកំលាំងសន្តិសុខស្រុកចាប់បានក្នុងអំឡុងពេលតវ៉ាដោយអហិង្សា ។ សកម្មជនបរិស្ថាន លោក ហ៊ុន វណ្ណៈ ក្រោយមកត្រូវបានមន្ត្រីនគរបាលស្លៀកពាក់ស៊ីវិលចាប់ខ្លួន ខណៈដែលលោកកំពុងផ្សាយផ្ទាល់ពេលលោកវិលត្រលប់ពីការធ្វើបាតុកម្មវិញ ។

សកម្មជនទាំងពីរត្រូវបានចោទប្រកាន់ពីបទ "ញុះញង់ឲ្យមានភាពវឹកវរដល់សន្តិសុខសង្គម" តាមមាត្រា ៤៩៤ និង៤៩៥នៃក្រមព្រហ្មទណ្ឌ ដែលអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ពីរឆ្នាំ ។ ហ៊ុន វណ្ណៈ ត្រូវបានឃុំខ្លួននៅនៅមណ្ឌលអប់រំកែប្រែទី១ (ម១) និង ឈឿន ដារ៉ាវី ត្រូវបានឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី២ (ម២) ។ ចំណែកឯយុវជន ០៤នាក់ ផ្សេងទៀត ត្រូវបានដោះលែងឲ្យមានសេរីភាពវិញ បន្ទាប់ពីត្រូវបានដាក់សម្ពាធធ្វើកិច្ចសន្យាថានឹងមិនធ្វើការតវ៉ាផ្សេងៗបន្តទៀតទេ ។

ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

## សកម្មជនបរិស្ថានម្នាក់ជាប់ពន្ធនាគារ ដោយសារធ្វើយុទ្ធនាការដើរម្នាក់ឯង

សកម្មជនបរិស្ថានចំនួន០៣នាក់ មានឈ្មោះ ឡុង គន្ធា ភួន កែវរស្មី និង ថុន រដ្ឋា ត្រូវបានចាប់ខ្លួនដោយសារការគ្រោងនឹងធ្វើយុទ្ធនាគារដើរតែម្នាក់ឯងយកញត្តិទៅជូនសម្តេចនាយករដ្ឋមន្ត្រី ដើម្បីលើកឡើងពីក្តីកង្វល់នៃការលុបបឹងតាមោក ដែលស្ថិតនៅភាគខាងជើងនៃរាជធានីភ្នំពេញ ។ បីថ្ងៃក្រោយមក អ្នកទាំងបីត្រូវបានចោទប្រកាន់ពី បទញុះញង់ តាមបញ្ញត្តិមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនទៅពន្ធនាគារ ។ កែវរស្មី គឺជាយុវជនវ័យក្មេងជាងគេ ដែលនាងទើបតែមានអាយុ ១៩ឆ្នាំប៉ុណ្ណោះ ។

ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០

## អ្នកចម្រៀងរ៉េបវ័យក្មេងម្នាក់ត្រូវបានចាប់ខ្លួន

អ្នកចម្រៀងរ៉េបអាយុ២១ឆ្នាំ ឈ្មោះ គា សុគុណ ត្រូវបានចាប់ខ្លួននៅខេត្តសៀមរាម ក្រោយ៤ខែបន្ទាប់ពីលោកបានចេញផ្សាយបទចម្រៀងដែលមានចំណងជើងថា ដីខ្មែរ ដែលមានខ្លឹមសាររិះគន់ពីអំពើពុករលួយ និងវិសមភាពនៅក្នុងសង្គមកម្ពុជា ក៏ដូចជាការភ័យខ្លាចបាត់បង់ទឹកដីទៅប្រទេសជិតខាង ។ គាត់ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបានបញ្ជូនទៅពន្ធនាគារខេត្តសៀមរាប ។

ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០

## សកម្មសង្ឃមួយអង្គត្រូវបានចាប់ព្រះកាយជុំវិញការធ្វើបាតុកម្ម

សកម្មជនសង្ឃព្រះនាម កើត សារ៉ាយ និងជាអនុប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញាវ័ន្តខ្មែរ លោក មាន ព្រហ្មមុន្នី ត្រូវបាននគរបាលចាប់ខ្លួន/ព្រះកាយ ពាក់ព័ន្ធនឹងគម្រោងប្រមូលផ្តុំគ្នាតវ៉ាអហិង្សានៅទីលានប្រជាធិបតេយ្យ ដើម្បីអំពាវនាវសុំឱ្យមានការដោះលែងប្រធានសហជីព លោក រ៉ុង ឈុន ប្រធានគណបក្សខ្មែរឈ្មោះ លោក សួង សុភ័ណ្ឌ និងសមាជិកក្រុមយុវជនខ្មែរថាវរៈ អ្នកនាង ឈឿន ដារ៉ាវី និងលោក ហ៊ុន វណ្ណៈ ដែលត្រូវបានចាប់ខ្លួនកាលពីខែសីហា ។ ព្រះតេជគុណ កើត សារ៉ាយ ត្រូវបានចាប់ផ្សឹកកាលពីរសៀលថ្ងៃច័ន្ទ ហើយអ្នកទាំងពីរត្រូវបានតុលាការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ រួចត្រូវបានបញ្ជូនខ្លួនទៅកាន់ពន្ធនាគារព្រៃស ដើម្បីឃុំខ្លួនបណ្តោះអាសន្ន ។

ថ្ងៃបន្ទាប់ សមាជិកក្រុមយុវជន ខ្មែរថាវរៈ លោក ថា ឡាវី ត្រូវបានអាជ្ញាធរចាប់ខ្លួន នៅពេលដែលលោកបំរុងចេញពីរ៉ឺម៉កកង់បី ដើរទៅកាន់ទីលានប្រជាធិបតេយ្យ ដើម្បីចូលរួមតវ៉ាដោយអហិង្សាអំពាវនាវសូមឱ្យមានការដោះលែងមេដឹកនាំសហជីព លោក រ៉ុង ឈុន ។ សមាជិកក្រុមយុវជន ខ្មែរថាវរៈ ម្នាក់ទៀត កញ្ញា អេង ម៉ាឡៃ ត្រូវបាននគរបាលតាមដាន ក្រោយពីចូលរួមតវ៉ាអហិង្សា ហើយត្រូវបានចាប់ខ្លួន ក្រោយពេលដែលកញ្ញា ចាកចេញពីការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស (UNOHCHR) ។

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០

## សកម្មជនយុវជនម្នាក់ត្រូវបានចាប់ខ្លួន

សកម្មជន មួង សុភ័ក្រ្ត អាយុ២៤ឆ្នាំ ដែលត្រូវជាប្អូនរបស់ប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរ លោក មួង សូនី ត្រូវបានចាប់ខ្លួនដោយគ្មានដីកា ក្រោមការបង្គាប់បញ្ជាររបស់ស្នងការនគរបាលរាជធានីភ្នំពេញ លោក ស ថេត ដែលរឿងនេះទាក់ទងទៅនឹងការចូលរួមរបស់គាត់ក្នុងការធ្វើបាតុកម្ម ដែលបានគ្រោងទុកដោយទាមទារឱ្យមានការដោះលែងលោក រ៉ុង ឈុន ។ គាត់ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ន ។

www.licadho-cambodia.org